00747696



០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ផ/អ.ជ.ត.ក (...)

**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក (...)

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្ដីរបស់លោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១០ ខែតុលា ឆ្នាំ ២០១១

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 18-Oct-2011, 15:16
CMS/CFO: Phok Chanthan

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ អង្គជំនុំជម្រះ **សម្ងាត់/Confidential**

ចំណាត់ថ្នាក់ប្រភេទឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះ សាធារណៈ / Public

អាសន្ន: 31/01/2012

ឈ្មោះមន្ត្រីកត់ត្រា: Peang Tola

ហត្ថលេខា:

---

**បណ្ដឹងសាទុក្ខដាច់ដោយឡែកប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ**

---

**<u>ដាក់ដោយ៖</u>**

ក្រុមសហមេធាវីការពារក្ដីរបស់លោក នួន ជា:

លោក សុន អរុណ

លោក Michiel PESTMAN

លោក Victor KOPPE

លោក Andrew IANUZZI

**<u>ផ្ញើជូន ៖</u>**

ក្រុមមេធាវីការពារក្ដីទាំងអស់:

សហព្រះរាជអាជ្ញា:

លោកស្រី ជា លាង

លោក Andrew CAYLEY



Original EN: 00746636-00746658

លោក Jasper PAUW

លោក ព្រុំ ផល្លា

កញ្ញា Zara LOCKSHIN

មេធាវីនាំមុខតំណាងដើមបណ្តឹង

រដ្ឋប្បវេណី:

លោក ពេជ អង្គ

លោកស្រី Elisabeth SIMONNEAU-FORT

## I. សេចក្តីផ្តើម

១. អនុលោមតាមវិធាន ៣៥ វិធាន ១០៤ វិធាន ១០៥ និងវិធាន ១០៧ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ("វិធាន")[1] ក្រុមមេធាវីការពារក្តីរបស់លោក នួន ជា ("មេធាវីការពារក្តី") សូមដាក់បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់លោក នួន ជា ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ ("សេចក្តីសម្រេចដែលរងការជំទាស់"[2]) ដោយសារតែសេចក្តីសម្រេចនេះ បានច្រានចោលសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ អនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ("សំណើសុំអនុលោមតាមវិធាន ៣៥")[3]។ ដោយសំអាងទៅលើមូលហេតុដូចបានលើកឡើងខាងក្រោម មេធាវីការពារក្តីសូមអះអាងថា (ក) បណ្តឹងសាទុក្ខនេះអាចទទួលយកបាន (ខ) សេចក្តីសម្រេចដែលរងការជំទាស់នេះ មិនអាចការពារតាមផ្លូវច្បាប់បានទេ ដោយសារតែមូលហេតុមួយចំនួន (គ) អង្គជំនុំជម្រះតុលាការកំពូលអាច និងគួរតែសម្រេចទៅលើការតវ៉ាដែលមិនទាន់បានដោះស្រាយអំពីការជ្រៀតជ្រែកខាងនយោបាយចូលក្នុងកិច្ចការរបស់សាលាក្តីនេះ (ឃ) ហើយសវនាការផ្ទាល់មាត់ និងជាសាធារណៈទៅលើបញ្ហាដ៏សំខាន់ ដែលបានលើកឡើងនៅក្នុងបណ្តឹងសាទុក្ខនេះ នឹងពិតជាបម្រើដល់ផលប្រយោជន៍នៃយុត្តិធម៌។ ជាបឋម មេធាវីការពារក្តីយល់ឃើញថា សារណាបន្ទាន់នេះគួរត្រូវបានចាត់ថ្នាក់ថាជាឯកសារសាធារណៈ[4]។

---

[1] *សូមមើល* វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក (វិសោធនកម្មលើកទី ៨) ដែលត្រូវបានធ្វើវិសោធនកម្មនៅថ្ងៃទី ៣ ខែសីហា ឆ្នាំ ២០១១។

[2] ឯកសារ **E116៖** សម្ងាត់ "សេចក្តីសម្រេចលើសំណើរបស់ជនជាប់ចោទ នួន ជា ពាក់ព័ន្ធនឹងកិច្ចស៊ើបសួរ (ឯកសារ E51/3, E82, E88, និង E92) ចុះថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ ២០១១, ឯកសារ ERN 00729330–00729339 ("សេចក្តីសម្រេចដែលរងការជំទាស់")។ ***កំណត់សម្គាល់៖*** អត្ថបទជាសាធារណៈដែលបានកោសលុប នៃសេចក្តីសម្រេចដែលរងការជំទាស់ ក៏ត្រូវបានចេញដោយអង្គជំនុំជម្រះសាលាដំបូងផងដែរ។ ឯកសារនេះត្រូវបានចុះលេខ និងមានលេខ ERN ដូចគ្នា ព្រោះវាជាឯកសារសម្ងាត់។

[3] ឯកសារ **E82៖** សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ អនុលោមតាមវិធាន ៣៥" ចុះថ្ងៃទី ២៨ ខែមេសា ឆ្នាំ ២០១១ ឯកសារ ERN 00680941–00680955 ("សំណើសុំអនុលោមតាមវិធាន ៣៥")។

[4] ***កំណត់សម្គាល់៖*** បណ្តឹងសាទុក្ខនេះ មិនមានឯកសារណាដែលមិនទាន់បានផ្សព្វផ្សាយទូលំទូលាយដោយប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននោះទេ ហើយដោយសារតែសារៈសំខាន់ជាសាធារណៈនៃបញ្ហា ដែលបានលើកឡើងនៅក្នុងបណ្តឹងសាទុក្ខនេះ នោះការកំណត់ករណីនេះថាជាភាពសម្ងាត់ អាចគ្រាន់តែនាំឱ្យមានឧបសគ្គដល់ដំណើរការនីតិវិធីដែលត្រឹមត្រូវ និងមានតម្លាភាពតែប៉ុណ្ណោះ។ តាមពិតទៅ ការផ្សព្វផ្សាយជាសាធារណៈ ពិតជាអាចរារាំងមិនឱ្យមានការជ្រៀតជ្រែកខាងនយោបាយដោយមិនត្រឹមត្រូវបន្តទៅទៀត។ លើសពីនេះទៅទៀត ក្នុងខណៈដែលដីកាដែលរងការជំទាស់ត្រូវបានចាត់ថ្នាក់ជាសម្ងាត់ អង្គជំនុំជម្រះសាលា

## I. អង្គហេតុពាក់ព័ន្ធ និងប្រវត្តិនីតិវិធី

### ក. ការជ្រៀតជ្រែកខាងនយោបាយយូរអង្វែង និងនៅតែបន្តមាន ក្នុងកិច្ចការរបស់សាលាក្តីនេះ

២. ដើម្បីជាការសង្ខេបឲ្យខ្លី មេធាវីការពារក្តីសូមធ្វើការយោងទៅលើសំណើជាក់ស្តែងមួយចំនួន (និងឯកសារគាំទ្រជាមូលដ្ឋាន) ដែលមាននៅក្នុងសំណើសុំ ពាក្យសុំ អញ្ញត្រកម្ម និងបណ្តឹងឧទ្ធរណ៍មួយចំនួន (ទាំងអស់នេះហៅថា "សំណើរបស់មេធាវីការពារក្តី") ដែលបានដាក់នៅចន្លោះពីខែមីនា ឆ្នាំ ២០០៩ និង ខែមេសា ឆ្នាំនេះ[5]។ ដូចដែលបានបង្ហាញយ៉ាងច្បាស់នៅក្នុងឯកសារផ្សេងៗ

---

ដំបូងក៏បានចេញអត្ថបទជាសាធារណៈដែលមានកោសលុប ដែលក្នុងកថាខណ្ឌ ២១ និងលេខយោងជើងទំព័ររបស់ឯកសារនេះ (ដែលជាផ្នែកតែមួយគត់នៃសេចក្តីសម្រេចដែលរងការជំទាស់ ដែលបានយកមកសរសេរ និងពិភាក្សាឡើងវិញនៅក្នុងបណ្តឹងសាទុក្ខនេះ) ត្រូវបានផ្សព្វផ្សាយពេញលេញ។ សូមមើល កំណត់សម្គាល់ក្នុងលេខ ២ *ខាងលើ*។ អាស្រ័យហេតុនេះ ឯកសារនេះគួរត្រូវបានចាត់ថ្នាក់ជាឯកសារសាធារណៈ។ ទោះជាយ៉ាងណាក៏ដោយ មេធាវីការពារក្តីនឹងចាត់ទុកឯកសារនេះជាសាធារណៈ។

[5] *សូមមើល* ឯកសារលេខ **D158** "សំណើលើកទី ១១ សុំឲ្យបំពេញកិច្ចស៊ើបសួរ" ចុះថ្ងៃទី ២៧ ខែមីនា ឆ្នាំ ២០០៩ ឯកសារ ERN 00294816–00294830 ("សំណើលើកទី ១១") កថាខណ្ឌ ៤ ដល់ ១២។ ឯកសារលេខ **D158/5/1/1** "បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើលើកទី ១១ សុំឲ្យបំពេញកិច្ចស៊ើបសួរ" ចុះថ្ងៃទី ៤ ខែឧសភា ឆ្នាំ ២០០៩ ឯកសារលេខ ERN 00323238–00323255 ("បណ្តឹងឧទ្ធរណ៍ស្តីពីអំពើពុករលួយ") កថាខណ្ឌ ២ ដល់ ៦។ ឯកសារលេខ **D254** "សំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ" ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ ERN 00410838–00410848 កថាខណ្ឌ ៤ ដល់ ៧។ ឯកសារ **D254/2** [សេចក្តីបន្ថែមទៅលើ "សំណើលើកទី ១ សុំឲ្យបំពេញកិច្ចស៊ើបសួរ"] ចុះថ្ងៃទី ៧ ខែធ្នូ ឆ្នាំ ២០០៩ ឯកសារ ERN 00410958–00410960 កថាខណ្ឌ ៤។ ឯកសារ **D314/2/4** "បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ ក.ស.ច.ស សម្រេចអំពីសំណើរបស់ជនត្រូវចោទ នួន ជា និងជនត្រូវចោទ អៀង សារី សុំឲ្យកោះអញ្ជើញសាក្សី" ចុះថ្ងៃទី ១៦ ខែមីនា ឆ្នាំ ២០១០ ឯកសារ ERN 00484112–00484130 កថាខណ្ឌ ២ ដល់ ១២។ សំណុំរឿងពិសេសលេខ ០០២/១៧-០៦-២០១០-អ.វ.ត.ក/អបជ(០៩) ឯកសារលេខ ១ "បណ្តឹងសុំដិតចិត្តចៅក្រម យូ ប៊ុនឡេង" ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ២០១០ ឯកសារ ERN 00535168–00515181 កថាខណ្ឌ ២ ដល់ ១១។ ឯកសារ **D314/2/9** "សារណាបណ្តឹងឧទ្ធរណ៍បន្ថែមប្រឆាំងនឹងដីការបស់ ក.ស.ច.ស សម្រេចអំពីសំណើរបស់ជនត្រូវចោទ នួន ជា និងជនត្រូវចោទ អៀង សារី សុំឲ្យកោះអញ្ជើញសាក្សី" ចុះថ្ងៃទី ២២ ខែមិថុនា ឆ្នាំ ២០១០ ឯកសារ ERN 00539820–00539827 កថាខណ្ឌ ២ ដល់ ៥។ ឯកសារ **D384** "សំណើលើកទី ២ សុំឲ្យបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី ៧ ខែកក្កដា ឆ្នាំ ២០១០ ឯកសារ ERN 00549028–00549031 កថាខណ្ឌ ២។ សំណុំរឿងពិសេសលេខ ០០២/០៧-០៧-២០១០-អ.វ.ត.ក/អបជ(១០) ឯកសារលេខ ១ "សំណើលើកទី ២ សុំឲ្យបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី ៧ ខែកក្កដា ឆ្នាំ ២០១០ ឯកសារ ERN 00553229–00553250 កថាខណ្ឌ ៤ ដល់ ១៥ ។ ឯកសារ **E51/3** "អញ្ញត្រកម្មរួមបញ្ចូលគ្នា" ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ២០១១ ឯកសារ ERN 00648279–00648310 កថាខណ្ឌ ៤ ដល់ ១៤។ សំណើសុំដោយអនុលោមតាមវិធាន ៣៥ កថាខណ្ឌ ២ ដល់ ១៣។

វាពិតជាច្បាស់មិនអាចប្រកែកបានទេថា មន្ត្រី និង/ឬ ភ្នាក់ងារមួយចំនួននៃរាជរដ្ឋាភិបាលកម្ពុជា ("រាជរដ្ឋាភិបាលកម្ពុជា" និង "រដ្ឋាភិបាល") បានជ្រៀតជ្រែកដោយមិនត្រឹមត្រូវទាល់តែសោះចូលមកក្នុងកិច្ចការរបស់អង្គជំនុំជម្រះ និងកំពុងតែបន្តជ្រៀតជ្រែកបែបនេះតទៅទៀត។

៣. ខាងក្រោមនេះគឺជាការរំឭកឡើងវិញជាសង្ខេបនូវមូលដ្ឋានអង្គហេតុ ដែលបានលើកឡើងនៅក្នុងសំណើសុំរបស់មេធាវីការពារក្តី៖

ក) ដោយការលើកឡើងថា ការចោទប្រកាន់ពីអំពើពុករលួយនៅសាលាក្តីនេះ បានគំរាមកំហែងធ្វើឱ្យប៉ះពាល់ដល់ធម្មានុរូបរបស់សាលាក្តីនេះ និងដោយការជំទាស់តវ៉ាថា របបដែលមានការរៀបចំចាត់តាំងនៃអំពើពុករលួយក្នុងលក្ខណៈជាស្ថាប័នបែបនេះ គឺជាសញ្ញាណនៃការជ្រៀតជ្រែកយ៉ាងធំធេងរបស់រដ្ឋាភិបាល មេធាវីការពារក្តីបានស្នើសុំឱ្យលាតត្រដាងការពាក់ព័ន្ធណាមួយរបស់រាជរដ្ឋាភិបាលកម្ពុជា ដោយការផ្តួចផ្តើមដំណើរការនីតិវិធីនៅតុលាការជាតិ និងបន្ទាប់មកនៅ អ.វ.ត.ក[6]។ មកទល់នឹងថ្ងៃនេះ បញ្ហានេះមិនទាន់បានដោះស្រាយប្រកបដោយជំនឿទុកចិត្តនៅឡើយទេ ហើយការមន្ទិលសង្ស័យអំពើពុករលួយ[7] នៅតែបន្តមានប្រកបដោយការគំរាមកំហែងមកលើសាលាក្តីនេះ[8]។ ពិតហើយថា ក្រៅតែការចាត់វិធានការដោះស្រាយមួយចំនួនដែលគ្រាន់តែល្អមើលនោះ[9] មិនមានសញ្ញាណណាមួយដែលថា រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ម្ចាស់ជំនួយ ឬមន្ត្រីតុលាការនៃសាលាក្តីនេះ មានចេតនា និង/ឬ អាចចាត់វិធានការចាំបាច់ដើម្បីបំបាត់បញ្ហានេះឱ្យបានជ្រះស្រឡះនោះទេ។ ទោះជាក្នុង

---

[6] *កំណត់សម្គាល់៖* នៅថ្ងៃទី ៨ ខែមករា ឆ្នាំ ២០០៨ សមាជិកបីរូបនៃក្រុមមេធាវីការពារក្តីរបស់លោក នួន ជា បានដាក់បណ្តឹងព្រហ្មទណ្ឌមួយទៅតុលាការដំបូងក្រុងភ្នំពេញ ដោយចោទប្រកាន់ទៅលើសកម្មភាពពុករលួយនៅ អ.វ.ត.ក។ សាលាដំបូងនេះបានច្រានចោលពាក្យបណ្តឹង ដែលត្រូវបានប្តឹងឧទ្ធរណ៍ទៅមហាអយ្យការអមសាលាឧទ្ធរណ៍ រហូតដល់ថ្ងៃទី ២០ ខែតុលា ឆ្នាំ ២០០៩ នៅពេលដែលបណ្តឹងឧទ្ធរណ៍នេះត្រូវបានបដិសេធចោលយ៉ាងស្ងៀមស្ងាត់ នៅក្នុងការសម្រេចមួយយ៉ាងឆាប់រហ័សដោយមិនមានការជូនដំណឹងដល់មេធាវីការពារក្តី ឬមិនមានការស៊ើបអង្កេតបន្ថែមទៀតឡើយ។ *សូមមើល* Bridget di Certo សារព័ត៌មាន ឌឹ ឃែមបូឌា ដេលី "សាលាឧទ្ធរណ៍បានបិទសំណុំរឿងស្តីពីអំពើពុករលួយនៅសាលាក្តីខ្មែរក្រហមយ៉ាងស្ងៀមស្ងាត់" ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០១១។ *សូមមើលផងដែរ* សំណើសុំលើកទី ១១ បណ្តឹងឧទ្ធរណ៍ស្តីពីអំពើពុករលួយ។

[7] Ian Andrews, កាសែត *l'Osservatore Romano* ដែលមានចំណងជើងថា៖ "ឆ្នាំជនជាតិស្វីសជាប់ពាក់ព័ន្ធក្នុងរឿងអាស្រូវពុករលួយនៅរដ្ឋធានី Vatican" ចុះថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ១៩៧៥។

[8] *សូមមើល* សំណើសុំលើកទីដប់មួយ កថាខណ្ឌ ១៩-២០។

[9] *ជាឧទាហរណ៍ សូមមើល* ការបង្កើតការិយាល័យអ្នកផ្តល់ប្រឹក្សាឯករាជ្យ។

ករណីណាក៏ដោយ ការខិតខំប្រឹងប្រែងដ៏តិចតួចបំផុត ដូចដែលបានធ្វើកន្លងមក ត្រូវបានបាំងស្រមោលបាត់ ដោយសារថា របៀបរបបទូទៅដែលបានសម្របសម្រួល និងផ្តួចផ្តើមដោយលោក ស៊ាន វិសុទ្ធ និងតំណាងរបស់គាត់មួយចំនួនក្នុងរយៈពេលជាងបួនឆ្នាំកន្លងមកនេះ *នៅតែកើតមានមកទល់នឹងសព្វថ្ងៃនេះ*[10] ហើយប្រាក់ពីអំពើពុករលួយនោះបន្តហូរចូលទៅក្នុងហោប៉ៅរបស់បុគ្គលក្នុងរាជរដ្ឋាភិបាលកម្ពុជា ដោយខុសច្បាប់ និងប៉ះពាល់យ៉ាងខ្លាំងទៅដល់សុចរិតភាពនៃអ្នកដែលជាប់ពាក់ព័ន្ធទាំងអស់។ មេធាវីការពារក្តីបានប្រកាន់ជំហរយ៉ាងស៊ីសង្វាក់គ្នាថា បញ្ហានេះពិតជាកើតមានក្នុងចំណោមបុគ្គលិករបស់ អ.វ.ត.ក នៅក្នុងអង្គជំនុំជម្រះផ្សេងៗ។

ខ) ក្នុងខែកក្កដា ឆ្នាំ ២០០៩ លោក គង់ សំអុល រដ្ឋមន្ត្រីអមព្រះបរមរាជវាំងនៃរាជរដ្ឋាភិបាលកម្ពុជា បានជ្រៀតជ្រែកមកលើកិច្ចខិតខំប្រឹងប្រែងរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត (“ក.ស.ច.ស”) ដើម្បីស្តាប់ព្រះចម្លើយព្រះបិតាជាតិ នរោត្តម សីហនុ ហើយការជ្រៀតជ្រែកនេះ រារាំងយ៉ាងមានប្រសិទ្ធភាពមិនឱ្យភាគីនានានៅ អ.វ.ត.ក ទទួលបានឱកាសស្តាប់សក្ខីកម្មដ៏សំខាន់តែមួយគត់របស់ព្រះអង្គ[11]។ លើសពីនេះទៅទៀត សហចៅក្រមស៊ើបអង្កេតជាតិ លោក យូ ប៊ុនឡេង ដែលជាមន្ត្រីជាន់ខ្ពស់មួយរូបនៃរាជរដ្ឋាភិបាលកម្ពុជា បានបដិសេធមិនព្រមចុះហត្ថលេខាលើលិខិតរបស់ ក.ស.ច.ស ជាច្រើន ដែលស្វែងរកការសុំសម្ភាសន៍ជាមួយអតីតព្រះមហាក្សត្រ[12]។

គ) នៅក្នុងខែកញ្ញា ឆ្នាំ ២០០៩ លោក ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាបានប្រកាសជាសាធារណៈថា គាត់ជំទាស់ទៅនឹងការស្តាប់ចម្លើយមន្ត្រីជាន់ខ្ពស់នៃរាជរដ្ឋាភិបាលកម្ពុជាចំនួនប្រាំមួយរូប (“មន្ត្រីក្នុងជួររាជរដ្ឋាភិបាល ៦ រូប”) ក្នុងឋានៈជាសាក្សីនៅក្នុងសំណុំរឿង ០០២[13]។ ការបញ្ចេញមតិជាសាធារណៈរបស់លោក ខៀវ កាញារីទ្ធ ដែលជាអ្នកនាំពាក្យរបស់រាជរដ្ឋាភិបាលកម្ពុជា នៅក្នុងខែតុលា ឆ្នាំ ២០០៩ បានរំឭកឡើងវិញអំពីទស្សនៈ

---

[10] *កំណត់សម្គាល់៖* អំណះអំណាងនេះ គឺយោងទៅលើរបាយការណ៍ផ្សេងៗរបស់អ្នកដែលផ្តល់ព័ត៌មានជាសម្ងាត់។

[11] *សូមមើល* ឯកសារ No **D254** “សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ” ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ ERN 00410838–00410848 “សំណើសុំឆ្នាំ ២០០៩” កថាខណ្ឌ ៥។

[12] *សូមមើល* សំណុំរឿងលេខ ០០២/១៧-០៦-២០១០-អ.វ.ត.ក-អបជ(០៩) ឯកសារលេខ ១ “បណ្តឹងជំទាស់ទៅនឹងចៅក្រម យូ ប៊ុនឡេង” ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ២០១០ ឯកសារ 00535168–00515181 កថាខណ្ឌ ៥។

[13] *សូមមើល* សំណើសុំឆ្នាំ ២០០៩ កថាខណ្ឌ ៦។

របស់លោក ហ៊ុន សែន និងមានហេតុផលលើសលុបដែលគួរឲ្យជឿបានថា ជំហរដែលបានលើកឡើងដោយរដ្ឋាភិបាល នាំឲ្យមាន ដោយផ្ទាល់ ឬដោយប្រយោល នូវការខកខានមិនចូលខ្លួន របស់មន្ត្រីក្នុងជួររាជរដ្ឋាភិបាលទាំងប្រាំមួយរូប[14]។ "ប្រភពរបស់តុលាការ" ដែលមិនបានបញ្ជាក់ឲ្យបានច្បាស់លាស់ បានអះអាងបញ្ជាក់អំពីការមន្ទិលសង្ស័យនេះ[15]។

ឃ).តាំងពីមុនការចាប់ផ្តើមបើកកិច្ចដំណើរការនីតិវិធីនៅសាលាក្តីនេះមកម្ល៉េះ រាជរដ្ឋាភិបាលកម្ពុជាបានបញ្ជាក់ពីជំហររឹងមាំរបស់ខ្លួនជាសាធារណៈ ម្តងហើយម្តងទៀតថា មានតែអង្គនីតិប្រតិបត្តិរបស់រដ្ឋាភិបាលប៉ុណ្ណោះ ពុំមែនស្ថាប័នណាផ្សេងទៀតនោះទេ ទោះជាស្ថាប័នតុលាការក្តី ឬមិនតុលាការក្តី ជាអ្នក*កំណត់ទៅលើលក្ខខណ្ឌ*នៃការចោទប្រកាន់បន្ថែមទៀតក្រៅពី កាំង ហ្គេកអ៊ាវ (ហៅ "ឌុច") និង "មេដឹកនាំជាន់ខ្ពស់" បួននាក់ដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២។ រាជរដ្ឋាភិបាលកម្ពុជាបានបញ្ជាក់អំពីលក្ខខណ្ឌទាំងនេះច្បាស់ហើយថា៖ មិនមានការចោទប្រកាន់បន្ថែមទៀតនោះទេ។ នៅក្នុងចំណោមមនុស្សជាច្រើន អ្នកដែលចូលរួមនៅក្នុងការអនុវត្តរបៀបវារៈ ដែលបានជំរុញដោយហេតុផលនយោបាយមាន សហព្រះរាជអាជ្ញា ជា លាង សហចៅក្រម យូ ប៊ុនឡេង ចៅក្រមកម្ពុជានៅក្នុង អ.ប.ជ និងមន្ត្រីមួយចំនួននៃរាជរដ្ឋាភិបាលកម្ពុជា ដែលរួមទាំង លោក ខៀវ កាញារីទ្ធ។ មិនមានអ្វីគួរឲ្យសង្ស័យនោះទេថា ប្រធានស្ថាបនិកនៃផែនការនេះ គឺពិតជាលោក នាយករដ្ឋមន្ត្រី ហ៊ុន សែន បើទោះជាគាត់មិនមែនជាអ្នកអនុវត្តក៏ដោយ។ យោងតាមអ្នកសង្កេតការណ៍ឥតលម្អៀង អ្នកដែលមិនទំនងជាអ្នកសហការទាល់តែសោះនោះ គឺហាក់ដូចលោកសហចៅក្រមស៊ើបអង្កេត Siegfried Blunk នេះហើយ[16] ដែលបានបង្ហាញខ្លួនគាត់ថាជាដៃគូយល់ព្រមអនុវត្តតាមម្នាក់នៅក្នុងផែនការរបស់រដ្ឋាភិបាល រហូតមកទល់នឹងពេលថ្មីៗនេះ[17]។

---

[14] *ដូចខាងលើ* កថាខណ្ឌ ៧។

[15] *ដូចខាងលើ* កថាខណ្ឌ ៩។ *សូមមើលផងដែរ* ឯកសារ **D314/2/9** "សារណាបណ្តឹងឧទ្ធរណ៍បន្ថែមប្រឆាំងនឹងដីការបស់ ក.ស.ច.ស សម្រេចអំពីសំណើរបស់ជនត្រូវចោទ នួន ជា និងជនត្រូវចោទ អៀង សារី សុំឲ្យកោះអញ្ជើញសាក្សី" ចុះថ្ងៃទី ២២ ខែមិថុនា ឆ្នាំ ២០១០ ឯកសារ ERN 0539820–0539827 កថាខណ្ឌ ១៣ ដល់ ១៦។

[16] *សូមមើល* កថាខណ្ឌ ១០ ខាងក្រោម។

[17] *សូមមើល* John Hall ព្រឹត្តិប័ត្រព័ត៌មាន *The Wall Street* "ការបរាជ័យរបស់អង្គការសហប្រជាជាតិនៅក្នុងប្រទេសកម្ពុជា៖ ចៅក្រមជាតិដែលបានសម្របសម្រួល និងការចាត់ចែងមិនបានត្រឹមត្រូវរបស់បុគ្គលិកអន្តរជាតិ បាននាំឲ្យសាលាក្តីខ្មែរក្រហមជាប់គាំង" ចុះថ្ងៃទី ៣ ខែតុលា ឆ្នាំ ២០១១ (the 'Hall Op-Ed') ('Siegfried Blunk ចៅក្រមស៊ើបអង្កេតអន្តរជាតិដែលត្រូវបាន

តាមដែលមេធាវីការពារក្តីដឹង មកទល់នឹងថ្ងៃនេះ មិនមានឧប្បត្តិហេតុណាមួយក្នុងចំណោមឧប្បត្តិហេតុទាំងនេះ ត្រូវបានស៊ើបអង្កេតដោយស្ថាប័នណាមួយ ឬដោយមន្ត្រីណាម្នាក់នៃសាលាក្តីនេះ ឬដោយស្ថាប័នឯករាជ្យណាមួយនៅឡើយទេ[18]។

៤. ជាការគួរឱ្យកត់សម្គាល់ ចៅក្រមអន្តរជាតិពីររូបនៃ អ.ប.ជ បានទទួលស្គាល់ជាផ្លូវការអំពីលក្ខណៈធ្ងន់ធ្ងរនៃបញ្ហាទាំងឡាយ ដែលបានលើកឡើងដោយមេធាវីការពារក្តី[19]។ ប៉ុន្តែ គ្មានអ្វីគួរឱ្យភ្ញាក់ផ្អើលនោះទេថា ចៅក្រមអន្តរជាតិទាំងពីររូប មិនមានលទ្ធភាពបញ្ចុះបញ្ចូលសមភាគីខាងកម្ពុជាឱ្យងាកចេញពីបន្ទាត់នយោបាយរបស់រដ្ឋាភិបាលបានទេ[20]។ ទោះជាយ៉ាងណាក៏ដោយ

---

ជ្រើសតាំងដោយអង្គការសហប្រជាជាតិ ដែលកំពុងចូលរួមចាត់ចែងរឿងក្តីនេះ គឺជាអ្នកទទួលខុសត្រូវ។ ក្នុងខណៈដែលគេរំពឹងថា ចៅក្រមកម្ពុជាអាចធ្វើមិនឱ្យបានសម្រេចចំពោះការស៊ើបអង្កេត នោះវាគួរឱ្យភ្ញាក់ផ្អើលដែលថា មន្ត្រីអង្គការសហប្រជាជាតិបានធ្វើបែបនេះ។ យ៉ាងហោចណាស់ក៏មាន បុគ្គលិកអង្គការសហប្រជាជាតិចំនួនប្រាំរូបនៅក្នុងការិយាល័យរបស់លោកចៅក្រម Blunk បានលាលែងដើម្បីតវ៉ាចំពោះសេចក្តីសម្រេចបញ្ចប់ការស៊ើបអង្កេត ចំណែកឯអ្នកផ្សេងទៀតបានបដិសេធមិនទទួលយកកិច្ចសន្យាថ្មី ឬបដិសេធមិនទទួលយកការចាត់តាំងឱ្យបំពេញការងារជាថ្មីពីការិយាល័យរបស់ចៅក្រមរូបនេះ។ ក្នុងខណៈដែលសហព្រះរាជអាជ្ញាអន្តរជាតិ Andrew Cayley ជាទីគោរព បានប្តឹងឧទ្ធរណ៍ជំទាស់នឹងការបិទកិច្ចស៊ើបសួរភ្លាមៗទៅលើសំណុំរឿង ០០៣ សហចៅក្រមស៊ើបអង្កេតទាំងពីររូប រួមមានលោកចៅក្រម Blunk ផងបានបង្គាប់មានការកោសលុបសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ និងបានអះអាងថា សំណើរបស់គាត់បានលើកឡើងពីព័ត៌មានសម្ងាត់')។ *សូមមើលផងដែរ* អង្គការឃ្លាំមើលសិទ្ធិមនុស្ស៖ ("ប្រទេសកម្ពុជា: ចៅក្រមដែលស៊ើបអង្កេតលើឧក្រិដ្ឋកម្មរបស់ខ្មែរក្រហមគួរតែលាលែងពីមុខតំណែង។ ការិយាល័យកិច្ចការនីតិកម្មរបស់អង្គការសហប្រជាជាតិខកខានមិនបានចាត់វិធានការចំពោះការប្រព្រឹត្តខុសក្រមវិជ្ជាជីវៈ" ទីក្រុងញូវយ៉ក ចុះថ្ងៃទី ៣ ខែតុលា ឆ្នាំ ២០១១ ("សេចក្តីប្រកាសព័ត៌មានរបស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស")។

[18] *ប៉ុន្តែ សូមមើល* "សេចក្តីថ្លែងការណ៍របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិនៅ អ.វ.ត.ក" ចុះថ្ងៃទី ១០ ខែតុលា ឆ្នាំ ២០១១ (ដែលក្នុងនោះចៅក្រម Blunk បានសំអាងទៅលើការផ្តួចផ្តើមឱ្យមាន "ដំណើរការនីតិវិធីចោទប្រកាន់ពីបទមាក់ងាយតុលាការ")។ កំណត់សម្គាល់៖ មិនមានព័ត៌មានបន្ថែមទៀតទេ ...។

[19] *សូមមើល* ឯកសារ **D314/1/12** "សាលដីកាលើកទីពីរលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា និងលោក អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើសុំឱ្យកោះហៅសាក្សី" ចុះថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ ២០១០ ឯកសារ ERN 00600748–00600774 ("សាលដីកា អ.ប.ជ សម្រេចលើការកោះហៅសាក្សី") ជាពិសេស "មតិយោបល់របស់ចៅក្រម Catherine Marchi-Uhel និងចៅក្រម Rowan Downing "យោបល់ខ្វែង" កថាខណ្ឌ ៥ ("ដោយសារតែ ស.ច.ស ខកខាន មិនបានបំពេញកិច្ចម្តងហើយម្តងទៀត យើងយល់ឃើញថា ដោយពិចារណាលើ*លក្ខណៈធ្ងន់ធ្ងរនៃការចោទប្រកាន់*អំពីការជ្រៀតជ្រែកនោះអង្គបុរេជំនុំជម្រះត្រូវតែធ្វើអន្តរាគមន៍") (មានបញ្ជាក់បន្ថែម)។

[20] *សូមមើល ដូចខាងលើ* ជាពិសេស "មតិយោបល់របស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ផុល និងចៅក្រម ហួត វុទ្ធី"។

ក៏គំនិតយោបល់ដែលបានពិចារណារួចមកហើយរបស់ពួកគាត់ ដែលបង្ហាញអំពីទស្សនៈរបស់អ្នកសង្កេតការណ៍ឥតលម្អៀង គឺជាការស្តីបន្ទោសខ្លាំងៗចំពោះជំហររបស់ស្ថាប័ននៅក្នុង អ.វ.ត.ក ពាក់ព័ន្ធទៅនឹងការជ្រៀតជ្រែករបស់រាជរដ្ឋាភិបាលកម្ពុជា៖

> នៅពេលយើងពិនិត្យមើល [ភស្តុតាងដែលបានដាក់ដោយមេធាវីការពារក្តី] យើងយល់ឃើញថា *អង្គហេតុដែលបានដាក់ដោយសមហេតុផលបាននាំឱ្យយើងពិចារណាថា អង្គហេតុដែលបានលើកឡើងខាងលើ និងហេតុការណ៍ជាបន្តបន្ទាប់ បង្កើតជាហេតុផលជឿថា សមាជិកនៃរាជរដ្ឋាភិបាលម្នាក់ ឬច្រើន អាចជ្រៀតជ្រែកដោយចេតនាពិតប្រាកដលើសាក្សីដែលអាចមកផ្តល់សក្ខីកម្មនៅចំពោះមុខ ស.ច.ស។* ការរកឃើញនេះនៅតែបង្ហាញឱ្យឃើញ ដោយមិនគិតថាតើសាក្សីដែលត្រូវបានកោះហៅ អាច ឬមិនអាចមានហេតុផលច្រើនជាងមួយដើម្បីមិនមកផ្តល់សក្ខីកម្ម។ អង្គហេតុសំខាន់ជាងនេះមួយនោះគឺ យោបល់របស់លោក ខៀវ កាញារីទ្ធ ដែលបានចេញផ្សាយនៅក្នុងកាសែត *ភ្នំពេញប៉ុស្តិ៍* ថា "ជំហររបស់រដ្ឋាភិបាល គឺពួកគាត់មិនគួរផ្តល់សក្ខីកម្មនោះទេ" នៅពេលនិយាយយោងដល់មន្ត្រី ៦ រូប។ បរិបទ ដែលសេចក្តីថ្លែងការណ៍នេះបានលើកឡើង បាននាំឱ្យមានការជឿជាក់យ៉ាងខ្លាំងថា សេចក្តីថ្លែងការណ៍នេះអាចជាការជ្រៀតជ្រែក ឬ ផ្ទុះបញ្ចាំងអំពីកិច្ចខំប្រឹងប្រែងដទៃៗទៀត ក្នុងការរារាំងការស្តាប់សក្ខីកម្មរបស់មន្ត្រីទាំង ៦រូបនេះ។ [...] យោបល់របស់លោក ខៀវ កាញារីទ្ធ ធ្វើឱ្យយើងជឿថា មានហេតុផលគួរឱ្យជឿជាក់ថា គាត់ ឬបុគ្គលដែលគាត់ផ្តល់យោបល់ ដោយជំនួសមុខឱ្យនោះ អាចប៉ុនប៉ងដោយចេតនាពិតប្រាកដនៅក្នុងការគំរាមកំហែង ឬ បំភិតបំភ័យមន្ត្រីទាំង៦ រូប ឬ បើមិនដូច្នេះទេ ជ្រៀតជ្រែកលើការសម្រេចចិត្តរបស់មន្ត្រីទាំង ៦ រូបនេះ ទាក់ទងនឹងការអញ្ជើញរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិឱ្យផ្តល់សក្ខីកម្ម[21]។

តាមពិតទៅ ចៅក្រម Marchi-Uhel និង ចៅក្រម Downing បានស្នើថា ទោះបីជា "ក.ស.ច.ស ជាអង្គភាពស៊ើបសួររបស់ អ.វ.ត.ក ក៏ដោយ"[22] ក៏ ក.ស.ច.ស ប្រហែលជាមិនមែនជាអង្គភាពសមស្របជាងគេបង្អស់ "ដើម្បីដឹកនាំកិច្ចស៊ើបអង្កេតទៅលើការចោទប្រកាន់ថា មានការជ្រៀតជ្រែកនោះបានឡើយ"[23]។

៥. ចាប់តាំងពីបានដាក់សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ដោយអនុលោមតាមវិធាន ៣៥ មក អង្គការយុត្តិធម៌សង្គមសេរី ("OSJI") "បានអំពាវនាវចំនួនពីរដងរួចមកហើយ ឱ្យអង្គការសហប្រជាជាតិ

---

[21] យោបល់ខ្មែង កថាខណ្ឌ ៦ (មានបញ្ជាក់បន្ថែម)។

[22] *ដូចខាងលើ* កថាខណ្ឌ ៨។

[23] *ដូចខាងលើដែរ*។

ធ្វើការស៊ើបអង្កេតដោយឯករាជ្យទៅលើការចោទប្រកាន់ទាំងឡាយដែលថា សហចៅក្រមស៊ើបអង្កេតនៅសាលាក្តីខ្មែរក្រហមកំពុងតែរារាំងដោយចេតនា ទៅលើការស៊ើបអង្កេតក្នុងសំណុំរឿង ០០៣ និង ០០៤[24]។ ដោយការលើកមកនិយាយឡើងវិញនូវអនុសាសន៍ប្រហាក់ប្រហែលគ្នាដែលបានធ្វើឡើងកាលពីដើមឆ្នាំនេះ អង្គការឃ្លាំមើលដំណើរការក្តីបានចោទសួរម្តងទៀតអំពី "ឯករាជ្យភាពតុលាការ" របស់សហចៅក្រមស៊ើបអង្កេតទាំងពីររូបនេះ[25]។ ការយល់ព្រមយ៉ាងច្បាស់លាស់របស់ ក.ស.ច.ស ចំពោះការជំទាស់ទៅលើយុត្តាធិការទាំងមិនត្រឹមត្រូវរបស់រដ្ឋាភិបាល ទាក់ទងនឹងជនសង្ស័យដែលមិនបានបញ្ចេញឈ្មោះ (ជាផ្លូវការ) ក្នុងសំណុំរឿង ០០៣ និង ០០៤ ត្រូវបានបង្ហាញឱ្យដឹងនាពេលថ្មីៗនេះ ដោយអតីតអ្នកវិភាគរបស់ ក.ស.ច.ស និងអ្នកជំនាញខាងប្រទេសកម្ពុជាម្នាក់ឈ្មោះ Steve Heder[26]។ Anne Heindel ដែលជាទីប្រឹក្សាច្បាប់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ('DC-Cam') បានរិះគន់ដូចគ្នានេះដែរ ហើយជាពិសេស បានសម្តែងមតិនៅក្នុងការរិះគន់ជាទម្លាប់នាពេលបច្ចុប្បន្ន ទៅលើការបន្តគាំទ្រដល់របៀបវារៈរបស់រដ្ឋាភិបាល[27] ដែលជាជំហរមួយស៊ីសង្វាក់គ្នាទៅនឹងការរិះគន់មុនៗដូចគ្នានេះរបស់ David Scheffer និង Hans Correll ដែរក្នុងចំណោមអ្នកសង្កេតការណ៍ជាច្រើននាក់ ដែលបានទទួលព័ត៌មានគ្រប់ជ្រុងជ្រោយ[28]។

---

[24] Bridget di Certo *ការសែតភ្នំពេញប៉ុស្តិ៍* [អង្គការនេះអំពាវនាវឱ្យមានការស៊ើបអង្កេតល្អិតល្អន់ទៅលើសាលាក្តីខ្មែរក្រហម 'Group calls for KRT probe'] ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ ២០១១ ទំព័រ ២។ *សូមមើលផងដែរ* សារព័ត៌មាន ឌឹ ខែមបូឌា ដេលី [អង្គការឃ្លាំមើលរិះគន់ខ្លាំងៗចំពោះការប្រព្រឹត្តមកលើជនរងគ្រោះនៅសាលាក្តីនេះ 'Watchdog slams court's treatment of victims'] ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ ២០១១ ទំព័រ ២២។

[25] *ដូចខាងលើ*។

[26] *សូមមើល* Steve Heder (ជាមួយនឹង David Boyle) "ការពិនិត្យឡើងវិញទៅលើការចរចា ដែលនាំឱ្យឈានដល់ការបង្កើតយុត្តាធិការលើបុគ្គលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" ចុះថ្ងៃទី ១ ខែសីហា ឆ្នាំ ២០១១។

[27] *សូមមើលជាឧទាហរណ៍* May Titthara និង Thomas Miller៖ *កាសែតភ្នំពេញប៉ុស្តិ៍* (ជនសង្ស័យពីបទប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាមដែលទ្រុឌទ្រោម "មិនមានការភ័យខ្លាចនោះទេ") ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ ២០១១។ Thomas Miller, *កាសែតភ្នំពេញប៉ុស្តិ៍* ។ "ទីតាំងឧក្រិដ្ឋកម្មក្នុងសំណុំរឿង ០០៤ ត្រូវបានបង្ហាញឱ្យដឹង" ចុះថ្ងៃទី ៨ ខែសីហា ឆ្នាំ ២០១១។ Julia Wallace៖ *កាសែត ឌឹ ខែមបូឌា ដេលី* "ចៅក្រមសាលាក្តីខ្មែរកម្រិតចង្អៀតទៅលើនិយមន័យនៃដើមបណ្តឹងរដ្ឋប្បវេណីដើម្បីដកក្រុមគ្រួសារចេញ ចុះថ្ងៃទី ២១ ខែកក្កដា ឆ្នាំ ២០១១។ Mike Eckel៖ *ទស្សនាវដ្តីគោលនយោបាយអន្តរជាតិ* (តុលាការគ្មានឯករាជ្យរបស់ប្រទេសកម្ពុជា "Cambodia's Kangaroo Court" ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០១១។

[28] សូមមើល David Scheffer៖ "ប្រវត្តិចរចាទៅលើយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក" ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១១។ Heder៖ ទំព័រ ៤០ ដល់ ៤១ (""សរុបមក ដូចដែលលោក Hans Corell បានអះអាងថា "វាច្បាស់ក្រឡែតហើយ" ផ្តើមចេញពីច្បាប់កម្ពុជា និងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ដែលបានមកពីដំណើរការចរចារវាង

៦. ដោយបានពិនិត្យឡើងវិញយ៉ាងស៊ីជម្រៅទៅលើការវិវត្តរបស់ អ.វ.ត.ក មកទល់នឹងពេលនេះ លោក Mark Ellis ដែលជាប្រធានគណៈមេធាវីអន្តរជាតិ បានបោះពុម្ពផ្សាយការយល់ឃើញរបស់គាត់នាពេលថ្មីៗនេះ[29]៖

> របាយការណ៍នានា និងការចោទប្រកាន់អំពីកាជ្រៀតជ្រែកពីសំណាក់រដ្ឋាភិបាលមកលើការជ្រើសរើសចៅក្រមឱ្យមកបំពេញការងារនៅ អ.វ.ត.ក និងកិច្ចការទាំងឡាយរបស់ អ.វ.ត.ក រួមទាំងកង្វះតម្លាភាពផងនោះ បានធ្វើឱ្យមានការប្រឡាក់ប្រឡូស និងការបាត់បង់ជំនឿទុកចិត្តមកលើសាលាក្តីនេះ។ ដោយសារថា អ.វ.ត.ក ត្រូវបានបង្កើតឡើងដោយឈរលើមូលដ្ឋានមួយដែលទន់ខ្សោយនោះវិធានការកែតម្រូវបន្តបន្ទាប់មកទៀត អាចជាការពិបាក បើមិនដល់ថ្នាក់ទៅមិនរួចទេនោះ[30]។
>
> បទពិសោធន៍របស់ អ.វ.ត.ក បង្ហាញឱ្យឃើញថា ការការពារតាមផ្លូវច្បាប់ (de jure protections) ចំពោះឯករាជ្យភាពរបស់តុលាការ គឺមិនមានភាពគ្រប់គ្រាន់នោះទេ។ ខណៈដែលក្របខ័ណ្ឌច្បាប់របស់ អ.វ.ត.ក ស្របគ្នានឹងបទដ្ឋានអន្តរជាតិស្តីពីការជំនុំជម្រះក្តីដោយយុត្តិធម៌ និងដំណើរការក្តីប្រកបដោយភាពត្រឹមត្រូវក៏ដោយ ក៏ អ.វ.ត.ក មិនបានអនុវត្តឱ្យស្របតាមព្រឹត្តិហេតុ

---

អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា បានរៀបរាប់ថា ច្បាប់ និងកិច្ចព្រមព្រៀងនេះបានកំណត់ (ជនសង្ស័យពីរប្រភេទ៖ មេដឹកនាំជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មទាំងឡាយ") និងថាការលើកឡើងផ្ទុយពីនេះគឺ "ហួសពីតថភាពពិតហើយ"។

[29] *សូមមើល* អត្ថបទបោះពុម្ពផ្សាយរបស់ Mark Ellis *គណៈមេធាវីអន្តរជាតិ* (IBA) "ការធានាចំពោះឯករាជ្យភាពតុលាការនៅក្នុងតុលាការចម្រុះ៖ មេរៀនដែលបានមកពី អ.វ.ត.ក និងការអនុវត្តជាក់ស្តែងដ៏ប្រសើរបំផុតសម្រាប់អនាគត" ចុះខែ កញ្ញា ឆ្នាំ ២០១១ (របាយការណ៍របស់ IBA)។ កំណត់សម្គាល់៖ "ខ្ញុំជាអ្នកគាំទ្រដល់ [អ.វ.ត.ក] ដំបូងគេម្នាក់។ ស្របជាមួយជំនឿរបស់ខ្ញុំដែលថា យើងទាំងអស់គ្នាត្រូវតែប្រយុទ្ធប្រឆាំងនឹងនិទ្ទណ្ឌភាព តាមរយៈការទទួលខុសត្រូវ ខ្ញុំបានជឿជាក់ទៅលើបេសកកម្មរួមរបស់ អ.វ.ត.ក រួមទាំងសមត្ថភាពរបស់សាលាក្តីនេះក្នុងការផ្តល់យុត្តិធម៌ជូនជនរងគ្រោះ និងភាពត្រឹមត្រូវចំពោះកំណត់ត្រាជាប្រវត្តិសាស្ត្រនេះ។ ប៉ុន្តែ នៅពេលដែលសកម្មភាពរបស់ អ.វ.ត.ក បានកើនឡើង ជំនឿទុកចិត្តរបស់ខ្ញុំចំពោះដំណើរការជម្រះក្តីរបស់តុលាការនេះ បានចាប់ផ្តើមថយចុះទៅវិញ។ ខ្ញុំបានកត់សម្គាល់ឃើញនូវការកើនឡើងបញ្ហាមួយចំនួនដែលបានធ្វើឱ្យខ្ញុំចោទសួរទៅលើបញ្ហាធម្មានុរូបរបស់សាលាក្តីនេះ។ ខ្ញុំក៏បានដឹងផងដែរថា ការព្រួយបារម្ភបែបនេះ គឺពាក់ព័ន្ធនឹងការចូលខ្លួនរបស់ចុងចោទនៅចំពោះមុខ អ.វ.ត.ក។ ក្រោយមកទៀត ខ្ញុំបានជួបជាមួយសហមេធាវីបរទេសការពាររឿងក្តីរបស់ នួន ជា គឺលោក Michiel Pestman និងលោក Victor Koppe។ ខ្ញុំបានលើកឡើងពីចំណាប់អារម្មណ៍របស់ខ្ញុំក្នុងការពិនិត្យមើលឱ្យកាន់តែស៊ីជម្រៅខ្លាំងឡើងទៅលើការព្រួយបារម្ភរបស់ខ្ញុំចំពោះ អ.វ.ត.ក។ ខ្ញុំបានស្នើសុំចូលរួមជាមួយក្រុមមេធាវីការពារក្តីរបស់ពួកគាត់ និងបានស្នើសុំការអនុញ្ញាតដើម្បីធ្វើសេចក្តីព្រាងរបាយការណ៍នេះ។ ពួកគាត់បានយល់ព្រម" របាយការណ៍របស់ IBA ទំព័រ ៦។

[30] របាយការណ៍របស់ IBA ទំព័រ ១០។

នោះទេ [...] ដោយសារតែកង្វះការធានាការអនុវត្តជាក់ស្តែងឱ្យមានប្រសិទ្ធភាព។ ក្រៅពីការការពារតាមផ្លូវច្បាប់ទាំងនេះ ការព្រួយបារម្ភដំបូងៗអំពីភាពខ្វះខាតនៅក្នុងប្រព័ន្ធតុលាការកម្ពុជាជ្រាបចូលមកក្នុងដំណើរការនីតិវិធីរបស់ អ.វ.ត.ក បានចេញជាផ្លែផ្កាហើយ។ ការចោទប្រកាន់មួយចំនួនត្រូវបានគេរាយការណ៍ថា មានការកើនឡើងអំពីការមន្ទិលសង្ស័យចំពោះឯករាជ្យភាព និងអនាគតិភាពរបស់ អ.វ.ត.ក។ ការចោទប្រកាន់ទាំងនេះ បានជាប់ប្រឡាក់ប្រឡូសទៅនឹងធម្មានុរូបរបស់ អ.វ.ត.ក និងធ្វើឱ្យអន្តរាយដល់ប្រតិបត្តិការនៅក្នុងការអនុវត្តជាក់ស្តែងរបស់តុលាការនេះ[31]។

អនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ការគំរាមកំហែងមកលើសាក្សីដែលអាចកើតមាន [...] តម្រូវឱ្យមានការឆ្លើយតបពីសំណាក់តុលាការ[32]។

បញ្ហាពាក់ព័ន្ធជាមួយនឹង អ.វ.ត.ក មិនមែនកើតពីការខកខានមិនបានផ្តល់មតិយោបល់នោះទេ។ ផ្ទុយទៅវិញ បញ្ហាទាំងនេះគឺបណ្តាលមកពីការខកខានរបស់សហគមន៍អន្តរជាតិដើម្បីការធានាឱ្យសាលាក្តីនេះឆ្លើយតបទៅនឹងបទដ្ឋានអន្តរជាតិស្តីពីភាពត្រឹមត្រូវ[33]។

ដោយហេតុថា សវនាការលើកដំបូងរបស់ អ.វ.ត.ក ត្រូវបានគេមើលឃើញថា គឺជាព្រឹត្តិការណ៍ដ៏ខ្លាំងក្លា និងមានសារប្រយោជន៍សម្រាប់ប្រជាជនកម្ពុជាដ៏ច្រើននាក់ វាអាចជាការទាក់ទាញដើម្បីកំណត់ការសន្មតមួយដែលជាប្រយោជន៍ដល់ការយោគយល់គ្នា ដែលចាំបាច់ដើម្បីបង្កើតតុលាការមួយ ទោះបីជាតុលាការដែលមានភាពខ្វះចន្លោះក៏ដោយ។ អ្នកខ្លះអាចជំទាស់តវ៉ាថា ទោះបីជា អ.វ.ត.ក ខកខានមិនបានឆ្លើយតបទៅនឹងបទដ្ឋានអន្តរជាតិក៏ដោយ ក៏តុលាការនេះបានបំពេញកិច្ចការលើសពីបទដ្ឋាននៅក្នុងប្រទេសកម្ពុជាដែរ។ ប៉ុន្តែ មានការប្រឈមមុខច្រើនទៀតក្រៅពីការបង្កើននីត្យានុកូលភាពនៃសវនាការតែមួយលើកនេះ។ ទោះបីជាអ្នកសិក្សាស្រាវជ្រាវជាច្រើនអាចជជែកពិភាក្សាគ្នាទៅលើការអះអាង ថាតើ អ.វ.ត.ក មានជោគជ័យ ឬបរាជ័យត្រឹមកម្រិតណាមួយនោះក៏ដោយ *ក៏វាមិនមានអ្វីដែលគួរឱ្យឆ្ងល់ទេថា អង្គការសហប្រជាជាតិបានប្រគល់ត្រាសម្គាល់របស់ខ្លួនទៅឱ្យតុលាការមួយ ដែលឯករាជ្យភាពរបស់តុលាការនេះមិនបានឆ្លើយតបទៅនឹងបទដ្ឋានអន្តរជាតិស្តីពីដំណើរការជំនុំជម្រះក្តី ប្រកបដោយភាពត្រឹមត្រូវរួចទៅហើយ*។ នៅក្នុងការពឹងអាស្រ័យធម្មានុរូបរបស់ អ.វ.ត.ក ទៅលើធម្មានុរូបរបស់តុលាការកម្ពុជា អ.វ.ត.ក បានធ្វើឱ្យសញ្ញាណរបស់អង្គការសហប្រជាជាតិចុះខ្សោយ នៅក្នុងរង្វង់នៃការ

---

[31] របាយការណ៍របស់ IBA ទំព័រ ២១។

[32] *ដូចខាងលើ* ទំព័រ ២៦។

[33] *ដូចខាងលើ* ទំព័រ ៤៥។

ទទួលខុសត្រូវដែលត្រូវមានលក្ខណៈជាអន្តរជាតិ[34]។

ខុសពីអ្នករិះគន់មុនៗ ដែលប្រហែលជាអ្នករិះគន់ផង និងជាអ្នកមានគោលបំណងសុចរិត ដោយគ្មានមន្ទិល និងដែលចង់ឃើញការទទួលបានជោគជ័យនៃយុត្តិធម៌អន្តរជាតិ បានបញ្ឈប់ការបន្ទោសទៅលើសមត្ថភាពខ្ពស់បំផុតរបស់តុលាការ និងសង្ឃឹមថា តុលាការនេះអាចទទួលបានលទ្ធផលចុងក្រោយដែលអាចទទួលយកបាននោះ បណ្ឌិត Ellis បានសន្និដ្ឋានយ៉ាងច្បាស់លាស់ថា ការបន្តដើរតាមមាគ៌ាបច្ចុប្បន្ន អាចប្រៀបប្រដូចទៅនឹងការសមគំនិតនៅក្នុងគម្រោងយុត្តិធម៌ដែលមានគុណវិបត្តិដ៏គ្រោះថ្នាក់បំផុត។

៧. ក្រៅពីរបាយការណ៍ដាច់ដោយឡែកៗ ដែលធ្វើឡើងដោយអ្នកនិយាយដោះសាររបស់រាជរដ្ឋាភិបាលកម្ពុជា[35] មិនមានអ្នកអត្ថាធិប្បាយដោយឯករាជ្យណាម្នាក់ ខកខានមិនបានឮអំពីការរិះគន់នេះទេ។ សូម្បីតែលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ បាន គីមូន ក៏ហាក់បីដូចជាមានការស្ទាក់ស្ទើរចំពោះការសម្រេចធ្វើការតែងតាំងមន្ត្រីតុលាការ នៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេតដែរ។ អ្វីដែលប្រសើរបំផុតដែលអ្នកនាំពាក្យរបស់គាត់បានលើកឡើងនៅពេលថ្មីៗបំផុតនោះ គឺជាសម្តីគ្មានតម្លៃគួរឱ្យធុញទ្រាន់ដែលថា៖ "អង្គការសហប្រជាជាតិ*រំពឹង*ថា ដំណើរការក្តីនេះពិតជាគេចផុតពីការជ្រៀតជ្រែកពីខាងក្រៅ[36]។ ប៉ុន្តែ នៅពេលដែលបានសួរត្រង់ចំណុចដែលថា តើចៅក្រម Blunk បានទទួលការគាំទ្រពីលោក បាន គីមូន និងអ្នកផ្សេងទៀតនៅឯបូរីអង្គការសហប្រជាជាតិដែរ ឬយ៉ាងណានោះ អ្នកនាំពាក្យរូបនេះ "មិនបានឆ្លើយតបនោះឡើយ"[37]។ វាហាក់បីដូចជាថា "សម្តីរបស់ អ.ស.ប" គឺជារឿងធម្មតាទៅហើយ ព្រោះសេចក្តីរំពឹងទុក និង

[34] *ដូចខាងលើ* ទំព័រ ៤៦ (មានបញ្ជាក់បន្ថែម)។

[35] *សូមមើលជាឧទាហរណ៍ នូវអត្ថបទសារព័ត៌មានរបស់* Douglas Gillison *កាសែត ឌឹ ឃែមបូឌា ដេលី* ដែលមានចំណងជើងថា៖ "ជា លាង បានចេញសេចក្តីថ្លែងការណ៍ឆ្លើយតបយ៉ាងរួសរាន់ទៅលើសំណុំរឿង ០០៣" ចុះថ្ងៃទី ១១ ខែឧសភា ឆ្នាំ ២០១១។

[36] Robert Carmichael, *វិទ្យុសំឡេងសហរដ្ឋអាមេរិក* "សាលាក្តីខ្មែរក្រហមនៅក្នុងប្រទេសកម្ពុជារងការរិះគន់ថ្មីជាច្រើន" ថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ២០១១ (មានបញ្ជាក់បន្ថែម) ("Martin Nesirky អ្នកនាំពាក្យរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ បាន គីមូន "Ban Ki-moon" បានលើកឡើងនៅក្នុងអ៊ីមែលមួយថា អង្គការសហប្រជាជាតិរំពឹងថា ដំណើរការជំនុំជម្រះក្តីត្រូវជៀសឱ្យផុតពីការជ្រៀតជ្រែកពីខាងក្រៅ")។

[37] *ដូចខាងលើ* ("Nesirky មិនបានឆ្លើយតបទៅនឹងសំណួរថាតើចៅក្រម Siegfried Blunk ដែលត្រូវបានជ្រើសតាំងដោយអង្គការសហប្រជាជាតិ នៅតែទទួលបានការគាំទ្រពីលោក បាន គីមូន និងបញ្ជាការរដ្ឋានរបស់អង្គការសហប្រជាជាតិដែរយ៉ាងណានោះទេ)។

តថភាពពិតកម្រនឹងដើរព្រមគ្នាណាស់[38]។

៨. យោងទៅលើការវិវត្តិនានា អង្គការឃ្លាំមើលសិទ្ធិមនុស្ស (Human Rights Watch) បានអំពាវនាវឲ្យសហចៅក្រមស៊ើបអង្កេតទាំងពីររូបលាលែងពីមុខតំណែង ដោយលើកឡើងថា សហចៅក្រមស៊ើបអង្កេតទាំងពីររូបនេះ "បានរំលោភយ៉ាងធ្ងន់ធ្ងរទៅលើកាតព្វកិច្ចផ្លូវច្បាប់ និងវិជ្ជាជីវៈរបស់ខ្លួន"[39]។ លោក Brad Adams ដែលជានាយកប្រចាំការនៅអាស៊ីរបស់អង្គការនេះ និងជាអ្នកឃ្លាំមើលដំណើរការនីតិវិធីនៅ អ.វ.ត.ក ជាយូរយារមកហើយនោះ បានផ្តល់នូវការវាយតម្លៃយ៉ាងសោះកក្រោះអំពីស្ថានភាព ដែលមើលឃើញជាទូទៅនៅទីតាំងចោមចៅថា៖

> ចាប់តាំងពីការបង្កើតសាលាក្តីនេះមក អ.វ.ត.ក បានប្រឈមមុខទៅនឹងការជ្រៀតជ្រែកដោយសារមូលហេតុនយោបាយជាញឹកញាប់ ពីសំណាក់គណបក្សប្រជាជនកម្ពុជាដែលកំពុងតែកាន់អំណាច។ មេដឹកនាំជាច្រើនរូបនៃរដ្ឋាភិបាលសព្វថ្ងៃ គឺជាអតីតកម្មាភិបាលខ្មែរក្រហម។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន *ដែលត្រួតត្រាតុលាការកម្ពុជា* ដែលមាន អ.វ.ត.ក បង្កប់នៅក្នុងនេះដែរនោះ បាននិយាយម្តងហើយម្តងទៀតថា គាត់ជំទាស់នឹងចំណាត់ការសំណុំរឿង ០០៣ និង ០០៤។ ប្រភពនានាពី អ.វ.ត.ក បានប្រាប់អង្គការឃ្លាំមើលសិទ្ធិមនុស្សឲ្យដឹងថា ការជ្រៀតជ្រែកខាងនយោបាយនេះគឺជាការបង្ហាញឲ្យឃើញពីការខកខានរបស់ចៅក្រម ក្នុងការស៊ើបអង្កេតរឿងក្តីឲ្យបានត្រឹមត្រូវ និងបណ្តាលឲ្យមានការលាលែងពីសំណាក់បុគ្គលិកមួយចំនួន នៅការិយាល័យសហចៅក្រមស៊ើបអង្កេត [...]។
>
> លោក Adams បាននិយាយថា "យើងខ្ញុំបានសម្តែងពីការព្រួយបារម្ភនេះជាយូរយារមកហើយថា ចៅក្រមកម្ពុជានៅសាលាក្តីខ្មែរក្រហមនេះមិនមានជម្រើសអ្វី ក្រៅតែពីការធ្វើទៅតាមអ្វីដែលលោក ហ៊ុន សែន និងមន្ត្រីជាន់ខ្ពស់ដទៃទៀតចង់បានតែប៉ុណ្ណោះ"។ "*អ.វ.ត.ក នឹងគ្រាន់តែខ្លាំងដូចគ្នានឹងទំនាក់ទំនងអន្តរជាតិដ៏ខ្សោយបំផុតរបស់ខ្លួនតែប៉ុណ្ណោះ។ ចៅក្រម **Blunk** គឺជាទំនាក់ទំនង*

[38] កំណត់សម្គាល់៖ ក្នុងន័យនេះ វាហាក់ដូចជាថា ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកទទួលបន្ទុកផ្នែកឧក្រិដ្ឋកម្មសង្គ្រាម លោក Stephen Rapp គឺជាវាគ្មិនដ៏ស្ទាត់ជំនាញម្នាក់។ ទាក់ទងទៅនឹងដំណាក់កាលដំបូងនៃកិច្ចការរបស់ចៅក្រម Blunk គាត់បាននិយាយពីបញ្ហានេះថា "ខ្ញុំជឿទៅលើភាពស្មោះត្រង់ដែលមាននៅក្នុងបុគ្គលម្នាក់ៗ ដែលខ្ញុំកំពុងតែនិយាយជាមួយ។ ពួកគេមានហេតុផលយ៉ាងល្អសម្រាប់ធ្វើអ្វីដែលពួកគេកំពុងធ្វើ។ Mike Eckel, *Associated Press*, "សាលាក្តីខ្មែរក្រហមរបស់ប្រទេសកម្ពុជាស្ថិតនៅក្នុងវិបត្តិ" ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០១១។ ចំពោះពាក្យសម្តីដែលត្រូវបានលើកឡើងក្នុងន័យប្រហាក់ប្រហែលគ្នា *សូមមើលផងដែរ* "សេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញា" ចុះថ្ងៃទី ៧ ខែតុលា ឆ្នាំ ២០១១ ("វចនាសម្ព័ន្ធតុលាការរបស់ [អ.វ.ត.ក] បង្ហាញពីកម្រិតនៃទំនុកចិត្តដែលសហគមន៍អន្តរជាតិបានប្រគល់មកឲ្យនៅក្នុងព្រះរាជាណាចក្រកម្ពុជា"។

[39] សេចក្តីប្រកាសព័ត៌មានរបស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស លេខយោង ១៧ *ខាងលើ*។

*នេះឯង*"។ [...]។

លោក Adams បាននិយាយទៀតថា ដោយការខកខានមិនបានឆ្លើយតបទៅនឹងការចោទប្រកាន់គួរឱ្យជឿជាក់បានមួយចំនួនអំពីការប្រព្រឹត្តផ្ទុយនឹងក្រមវិជ្ជាជីវៈនេះ "នោះអង្គការសហប្រជាជាតិកំពុងតែធ្វើមិនដឹងមិនឮចំពោះបញ្ហា[40]។ "ប្រសិនបើអង្គការសហប្រជាជាតិ មិនចាត់វិធានការឱ្យបានឆាប់រហ័សបំផុតដើម្បីធានាឱ្យមានការស៊ើបអង្កេតទៅលើករណីទាំងនេះឱ្យបានពេញលេញទេ *នោះជំនឿទុកចិត្តដ៏តិចតួចជាចុងក្រោយរបស់*សាលាក្តីនេះនឹងត្រូវបាត់បង់ ហើយអង្គការសហប្រជាជាតិនឹងត្រូវឆ្លើយទៅនឹងសំណួរពិបាកៗជាច្រើនអំពីសកម្មភាពរបស់ខ្លួន" [...]។

ការអំពាវនាវរបស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស បានធ្វើឡើងតែប៉ុន្មានថ្ងៃមុនពេល John Hall ដែលជាសាស្ត្រាចារ្យច្បាប់ និងជាអ្នកសង្កេតការណ៍ជាប់លាប់នៅសាលាក្តីនេះ បានធ្វើការកត់សម្គាល់ទាំងក្តីសោកស្តាយថា៖ [វាដល់ពេលវេលាដែលសហគមន៍អន្តរជាតិត្រូវដកខ្លួនចេញពីការទទួលខុសត្រូវដែលប្រឡាក់ប្រឡូសដោយនយោបាយ និងដែលចាត់ចែងមិនបានត្រឹមត្រូវគួរឱ្យខ្មាសអៀននេះហើយ][41]។

៩. ដោយមានការប្រតិកម្មទៅនឹងការរិះគន់កាន់តែខ្លាំងឡើងៗ រដ្ឋមន្ត្រីការបរទេសនៃរាជរដ្ឋាភិបាលកម្ពុជាត្រូវបានដកស្រង់សម្តីដែលគាត់បានមានប្រសាសន៍ថា៖ "មានតែកម្ពុជាទេទើបអាចសម្រេចថាតើជនសង្ស័យប៉ុន្មាននាក់បន្ថែមទៀត ដែលសាលាក្តីខ្មែរក្រហមនឹងធ្វើការចោទប្រកាន់នោះ"[42]។ ជាការឆ្លើយតប Iskander Pastrulo បានសង្ខេបបញ្ហានេះ ជាមួយនឹងគំនិតដោយលម្អៀងរបស់លោក ហោ ណាំហុង ទៅលើទស្សនៈស្តីពីការបែងចែកអំណាចថា៖

ខ្ញុំហៀបនឹងនិយាយអំពីការពិតទៅហើយ ប៉ុន្តែ ពេលខ្លះត្រូវតែយកការពិតមកនិយាយ។ នៅ អ.វ.ត.ក សេចក្តីសម្រេចបើកកិច្ចស៊ើបសួរ និងចោទប្រកាន់ទៅលើជនទាំងឡាយ ត្រូវផ្តួចផ្តើមគំនិតដោយសហព្រះរាជអាជ្ញា បន្ទាប់មក ដោយសហចៅក្រមស៊ើបអង្កេត ហើយក្នុងករណីមានការខ្វែងគំនិតគ្នា ឬមានការប្តឹងឧទ្ធរណ៍ ត្រូវសម្រេចដោយអង្គបុរេជំនុំជម្រះ។ គ្មានស្ថាប័នណាមួយក្នុងចំណោមស្ថាប័នទាំងបីដែលបានលើកឡើងខាងលើ អាចត្រូវបានយកមកបកស្រាយថាជា "ប្រទេសកម្ពុជា" នោះទេ។ ពិតហើយថា ការជះឥទ្ធិពលណាមួយពីសំណាក់រដ្ឋាភិបាល

---

[40] *ដូចខាងលើ* (មានបញ្ជាក់បន្ថែម)។

[41] Hall Op-Ed, លេខយោង ១៧ *ខាងលើ*។

[42] Julia Wallace និង Neou Vannarin, *កាសែត ឌឹ ខេមបូឌា ដេលី*, "ការចាប់ខ្លួនខ្មែរក្រហមបន្ថែមទៀត គឺស្ថិតនៅក្នុងដៃកម្ពុជា" ប្រសាសន៍របស់ លោក ហោ ណាំហុង កាលពីថ្ងៃទី ៥ ខែតុលា ឆ្នាំ ២០១១ ។

អាចបង្កទៅជាការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ[43]។

Montesquieu ខ្លួនគាត់ផ្ទាល់ក៏មិនអាចនិយាយឲ្យបានប្រសើរជាងនេះដែរ។

១០. ជាការឆ្លើយតបទៅនឹងព្រឹត្តិការណ៍ទាំងនេះ ចៅក្រម Blunk បានដាក់សំណើសុំលាលែងរបស់គាត់កាលពីថ្ងៃទី ៨ ខែតុលា ឆ្នាំ ២០១១៖

> បន្ទាប់ពីការតែងតាំងរូបគាត់នៅថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេតអន្តរជាតិនៃ អ.វ.ត.ក រូបនេះបានចាប់ដំណើរការស៊ើបសួរទៅលើសំណុំរឿង ០០៣ និង ០០៤ ដោយការរំពឹងទុកថា សេចក្តីថ្លែងការណ៍មុនមួយដែលបានថ្លែងឡើងដោយនាយករដ្ឋមន្ត្រីកម្ពុជា នៅក្នុងជំនួបប្រជុំជាមួយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិថា សំណុំរឿងទាំងនេះ "នឹងមិនត្រូវបានអនុញ្ញាត" មិនបានឆ្លុះបញ្ចាំងទៅនឹងគោលនយោបាយទូទៅរបស់រដ្ឋាភិបាលនោះទេ។
>
> ប៉ុន្តែ នៅថ្ងៃទី ១០ ខែឧសភា ឆ្នាំ ២០១១ លោករដ្ឋមន្ត្រីក្រសួងព័ត៌មានបានមានប្រសាសន៍ថា "ប្រសិនបើគេចង់បន្តទៅក្នុងសំណុំរឿង ០០៣ និង ០០៤ នោះពួកគេគួរតែវេចបង្វិចត្រឡប់ទៅផ្ទះវិញ"។ ទោះបីជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានផ្តួចផ្តើមដំណើរការនីតិវិធីពីបទមាក់ងាយតុលាការប្រឆាំងនឹងរូបគាត់ និងបានរំពឹងថា នេះជាការព្រមានដល់មន្ត្រីរដ្ឋាភិបាលដទៃទៀត ក៏កាលពីសប្តាហ៍មុន លោករដ្ឋមន្ត្រីក្រសួងព័ត៌មានបានមានប្រសាសន៍ម្តងហើយម្តងហើយទៀត "ចំពោះបញ្ហាចាប់ខ្លួនមេដឹកនាំបន្ថែមទៀតថា នេះជាបញ្ហាកម្ពុជា ...។ បញ្ហានេះត្រូវតែសម្រេចដោយកម្ពុជា"។
>
> ដោយសារតែសេចក្តីថ្លែងការណ៍ដដែលៗ ដែលត្រូវបានគេយល់ថា ជាការជ្រៀតជ្រែកដោយចេតនាពីសំណាក់មន្ត្រីរដ្ឋាភិបាលមកលើសំណុំរឿង ០០៣ និង ០០៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានដាក់ស្នើសុំលាលែងរបស់គាត់ជូនទៅលោកអគ្គលេខាធិការ កាលពីថ្ងៃទី ៨ ខែតុលា ឆ្នាំ ២០១១[44]។

រយៈពេលប៉ុន្មានថ្ងៃបន្ទាប់ពីការអំពាវនាវឲ្យគាត់លាលែងពីមុខតំណែង ការចាកចេញរបស់ចៅក្រម Blunk ទោះជាដោយមូលហេតុអ្វីក៏ដោយ ត្រូវបានគេយល់ថា ជាការចុះចាញ់ដោយសារតែការដាក់សម្ពាធពីអ្នកសង្កេតការណ៍អន្តរជាតិ។ ដោយការមើលទៅហាក់បីដូចជាអាយ៉ងរបស់

[43] Iskander Pastrulo លិខិតផ្ញើជូននិពន្ធនាយក *កាសែត ខឹ ភែមបូឌា ដេលី*, "ការចាប់ខ្លួនខ្មែរក្រហមបន្ថែមទៀតស្ថិតនៅលើតុលាការ មិនមែនស្ថិតនៅលើរដ្ឋាភិបាលនោះទេ" ពីថ្ងៃទី ៧ ខែតុលា ឆ្នាំ ២០១១ ។

[44] "សេចក្តីថ្លែងការណ៍របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិនៃ អ.វ.ត.ក" ពីថ្ងៃទី ១០ ខែតុលា ឆ្នាំ ២០១១ ។

រាជរដ្ឋាភិបាលកម្ពុជាជាយូរមកហើយ[45] និងមិនអាចពន្យល់បាន ឥឡូវនេះវាហាក់ដូចជាថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវបានគេស្រាយចំណង នៅក្នុងទិសដៅមួយដែលត្រឹមត្រូវ។

## ខ. កិច្ចខិតខំប្រឹងប្រែងរបស់មេធាវីការពារក្តីដើម្បីដោះស្រាយបញ្ហាទាំងនេះ

១១. ក្នុងអំឡុងនៃកិច្ចស៊ើបសួរ និងនៅដំណាក់កាលដំបូងៗនៃការជំនុំជម្រះ មេធាវីការពារក្តីបានធ្វើការខិតខំប្រឹងយ៉ាងខ្លាំងដើម្បី "ត្រួសត្រាយគន្លងវាយប៉ាយនេះ ឆ្ពោះទៅកាន់យុត្តិធម៌នៅក្នុងប្រទេសកម្ពុជា"[46] ដែលនាំឱ្យឈានដល់ការដាក់សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង កាលពីថ្ងៃទី ២៨ ខែមេសា ឆ្នាំ ២០១១[47]។ ក្នុងចំណោមបញ្ហាជាច្រើន សំណើសុំនោះបានស្នើសុំឱ្យមានការបញ្ជាក់ឱ្យបានច្បាស់លាស់ អំពីការជ្រៀតជ្រែកចូលក្នុងសំណុំរឿង ០០២ ទំនាក់ទំនងរវាងការជ្រៀតជ្រែកបែបនោះ និងទង្វើប្រហាក់ប្រហែលគ្នានៃការជ្រៀតជ្រែកចូលក្នុងសំណុំរឿង ០០៣ និង ០០៤ ព្យសនកម្មដែលមេធាវីការពារក្តីបានទទួលរង និងតុលាការនេះដែលជាស្ថាប័នមួយ និងហេតុការណ៍មុនៗស្តីពីការប្រព្រឹត្តផ្ទុយពីមុខងារតុលាការនិងរដ្ឋបាល[48]។ ប៉ុន្តែ ដូចគ្នានឹង ក.ស.ច.ស និង អ.ប.ជ ដែរ អង្គជំនុំជម្រះសាលាដំបូងមិនមានឆន្ទៈចាត់វិធានការណាមួយដើម្បីជាដំណោះស្រាយនោះទេ។

## គ. ដីកាដែលរងការជំទាស់

១២. តាមពិតទៅ សូម្បីតែមិនមានការបកស្រាយឱ្យបានរួសរាន់ទៅលើបញ្ហាសំខាន់ៗ ដែលបានលើកឡើងដោយមេធាវីការពារក្តីក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងបានសម្រេចទៅលើសំណើសុំដោយអនុលោមតាមវិធាន ៣៥ នៅក្នុងលក្ខណៈជាសង្ខេប៖

> ពាក់ព័ន្ធទៅនឹងការចោទប្រកាន់របស់ជនជាប់ចោទ អំពីការជ្រៀតជ្រែកទៅក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ ឬការជ្រៀតជ្រែកខាងនយោបាយនៅក្នុងសំណុំរឿងលេខ ០០៣ និង ០០៤

---

[45] *សូមមើល* Hall Op-Ed លេខយោង ១៧ ខាងលើ។

[46] ឯកសារលេខ **D158** "សំណើលើកទីដប់មួយសុំឱ្យបំពេញកិច្ចស៊ើបសួរ" ចុះថ្ងៃទី ២៧ ខែមីនា ឆ្នាំ ២០០៩ ឯកសារ ERN 00294816–00294830 កថាខណ្ឌ ២១។ *កំណត់សម្គាល់៖* មកទល់នឹងថ្ងៃនេះ មេធាវីការពារក្តីបានដាក់សំណើសុំដាច់ៗពីគ្នាចំនួនជាងមួយឡ ក្នុងគោលបំណងបង្ហាញពីចរិតពិត និងលុបបំបាត់ការជ្រៀតជ្រែកខាងនយោបាយមកលើ អ.វ.ត.ក តាមដែលអាចធ្វើទៅបាន។ *សូមមើលជាឧទាហរណ៍* លេខយោងជើងទំព័រ *៥ ខាងលើ*។

[47] *សូមមើល* លេខយោងជើងទំព័រ ៣ *ខាងលើ*។

[48] *សូមមើល* សំណើសុំដោយអនុលោមតាមវិធាណ ៣៥ កថាខណ្ឌ ២ ដល់ ១២ និងកថាខណ្ឌ ១៩ ដល់ ៣១។

> អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា [...] វិធាន ៣៥(២) នៃវិធានផ្ទៃក្នុង មានចែងអំពីកិច្ចស៊ើបសួរទៅលើការចោទប្រកាន់បែបនេះ "នៅពេលដែលសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះមានហេតុផលដែលនាំឱ្យជឿបានថា ជនណាម្នាក់បានធ្វើការជ្រៀតជ្រែកទៅក្នុងកិច្ចការរដ្ឋបាលតុលាការដោយបានដឹងជាមុន និងដោយចេតនា"។ វិធាននេះក៏បានចែងផងដែរថា កិច្ចស៊ើបសួរដែលធ្វើឡើងដោយអនុលោមតាមវិធាននេះ អាចនឹងត្រូវបានអនុវត្តដោយប្រសិទ្ធភាពដោយស្ថាប័នតុលាការដែលទទួលសំណុំរឿងនេះ។ ដោយសារក្នុងពេលបច្ចុប្បន្ន រឿងក្ដីទាំងអស់នេះកំពុងស្ថិតនៅក្នុងដំណាក់កាលស៊ើបសួរ ដូច្នេះ ជាដំបូង ស្ថាប័នដែលមានសមត្ថកិច្ចនោះគឺសហចៅក្រមស៊ើបអង្កេត ហើយបន្ទាប់មកគឺ អង្គបុរេជំនុំជម្រះ ក្នុងករណីមានបណ្ដឹងឧទ្ធរណ៍។ ដោយសារតែសំណើសុំលើកទីមួយដែលធ្វើឡើងតាមវិធាន ៣៥ មិនបានកំណត់អំពីផលប៉ះពាល់ជាក់ស្ដែងនៃការចោទប្រកាន់ទាំងអស់នេះទៅ លើភាពយុត្តិធម៌នៃកិច្ចដំណើរការជំនុំជម្រះក្ដីនៅក្នុងសំណុំរឿងលេខ ០០២ (ជាសំណុំរឿងដែលអង្គជំនុំជម្រះសាលាដំបូងបានទទួលនោះ) ហេតុដូច្នេះសំណើសុំនេះគប្បីត្រូវបានបដិសេធ[49]។

មិនមានការពិភាក្សាពាក់ព័ន្ធទៅនឹងការចោទប្រកាន់ ដែលទាក់ទងនឹងសំណុំរឿង ០០២ ត្រូវបានលើកឡើងនៅក្នុងដីកាដែលរងការជំទាស់នោះទេ បើទោះបីជាការចោទប្រកាន់ទាំងនេះត្រូវរៀបរាប់យ៉ាងច្បាស់នៅក្នុងសំណើសុំ ដោយអនុលោមតាមវិធាន ៣៥ ក៏ដោយ[50]។

១៣. ជាការគួរឱ្យកត់សម្គាល់ នៅក្នុងការបដិសេធសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងបានចង្អុលបង្ហាញទៅលើសេចក្ដីសម្រេចមុនមួយរបស់អង្គបុរេជំនុំជម្រះ ("អ.ប.ជ") ដោយការអះអាងដូចខាងក្រោម៖ 'វិធានផ្ទៃ ៣៥ មិនមានចែងអំពីការផ្ដួចផ្ដើមការបំពេញកិច្ចស៊ើបសួរ តាមការស្នើសុំរបស់ភាគីនោះទេ"[51]។

១៤. ពិសេសបំផុត អង្គជំនុំជម្រះសាលាដំបូង៖ (ក) មិនបានយកចិត្តទុកដាក់ទាល់តែសោះចំពោះការអះអាងដែលទាក់ទងដោយផ្ទាល់ទៅនឹងសំណុំរឿង ០០២ និងមិនបានផ្ដល់សំអាងហេតុចំពោះការខកខានបែបនេះឡើយ (ខ) បានយល់ឃើញថា ស្ថាប័នរបស់ អ.វ.ត.ក អាចបំពេញកិច្ចបាន ដោយ

---

[49] ដីកាដែលរងការជំទាស់ កថាខណ្ឌ ២១ (ការបញ្ជាក់ខាងក្នុងត្រូវបានលុបចោល)។

[50] *សូមមើល* កថាខណ្ឌ ២៤ និងកថាខណ្ឌ ៣៤ *ខាងក្រោម*។

[51] ដីកាដែលរងការជំទាស់ លេខយោង ៤៥ (សំអាងទៅលើឯកសារលេខ **D158/5/1/15** "សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើសំណើលើកទីដប់មួយរបស់ជនត្រូវចោទ សុំឱ្យបំពេញកិច្ចស៊ើបសួរ" ចុះថ្ងៃទី ១៨ ខែសីហា ឆ្នាំ ២០០៩ ឯកសារ ERN 00364033–00364046 កថាខណ្ឌ ២៩។

អនុលោមតាមវិធាន ៣៥ តែប៉ុណ្ណោះ នៅពេលដែលការអះអាងទាំងនោះទាក់ទងដោយផ្ទាល់ទៅនឹងបញ្ហាអង្គហេតុដែលស្ថាប័ននោះបានទទួល (គ) បានបដិសេធសំណើសុំដោយអនុលោមតាមវិធាន ៣៥ ដោយយោងទៅលើមូលដ្ឋានទាក់ទងទៅនឹងការអះអាងលើអង្គហេតុ ដែលទាក់ទងនឹងសំណុំរឿង ០០៣ និង ០០៤ និង (ឃ) បានបង្គាប់ថា ភាគីទាំងឡាយមិនអាចផ្តួចផ្តើមដំណើរការនីតិវិធីស្របតាមវិធាន ៣៥ តាមរយៈសំណើសុំដោយផ្ទាល់របស់ខ្លួនបានទេ។ ដូចដែលបានជំទាស់តវ៉ាជាលម្អិតខាងក្រោមនេះ គ្មានជំហរណាមួយក្នុងចំណោមជំហរទាំងនេះ មានលក្ខណៈសមហេតុសមផលនោះទេ។

## II. ច្បាប់ពាក់ព័ន្ធ

### ក. ការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ

១៥. វិធាន ៣៥(១) នៃវិធានផ្ទៃក្នុងចែងដូចតទៅ៖

> អង្គជំនុំជម្រះវិសាមញ្ញអាចដាក់ទណ្ឌកម្ម ឬ បញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ចនូវជនណាម្នាក់ដែលជ្រៀតជ្រែកដោយចេតនាពិតប្រាកដ ក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ រួមទាំងបុគ្គលដែល៖ [...] (ខ) ដោយគ្មានមូលហេតុសមស្រប បុគ្គលដែលមិនគោរពតាមសេចក្តីបង្គាប់ឱ្យចូលរួមក្នុងដំណើរការជម្រះក្តី ឬ មិនផ្តល់ឯកសារ ឬ ភស្តុតាងផ្សេងទៀតឱ្យសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ។ [...] (ឃ) គំរាមកំហែង បំភិតបំភ័យ បង្ករបួសស្នាម ឬ ផ្តល់សំណូក ឬ ក៏ជ្រៀតជ្រែកលើសាក្សីណាម្នាក់ ឬ លើអ្នកដែលអាចក្លាយជាសាក្សីដែលកំពុងផ្តល់ បានផ្តល់ ឬ អាចផ្តល់ភស្តុតាងដល់សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ។ (ង) គំរាមកំហែង បំភិតបំភ័យ ឬសូកសំណូក ឬ ស្វែងរកវិធីគាបសង្កត់លើបុគ្គលដទៃទៀតក្នុងបំណងទប់ស្កាត់បុគ្គលនោះមិនឱ្យអនុវត្តតាមដីការបស់សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ។ (ឆ) ញុះញង់ ឬ ប៉ុនប៉ងប្រព្រឹត្តអំពើណាមួយដូចមានចែងខាងលើ។

នៅពេលដែលសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ*ណាមួយ* "មានហេតុផលជឿថា បុគ្គលណាម្នាក់*អាចធ្លាប់បានប្រព្រឹត្ត*អំពើណាមួយ ដូចមានចែងក្នុង វិធាន ៣៥(១) ខាងលើ សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ អាច៖ (ក) ចាត់ការជាមួយបញ្ហានេះជាបន្ទាន់។ (ខ) ដឹកនាំការស៊ើបសួរបន្ថែម ដើម្បីឱ្យដឹងប្រាកដថាតើមានមូលដ្ឋានគ្រប់គ្រាន់សម្រាប់ចាត់ការតាមនីតិវិធី ។ ឬ (គ) បញ្ជូនបញ្ហានេះទៅឱ្យអាជ្ញាធរមានសមត្ថកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា ឬ អង្គការសហ

ប្រជាជាតិ"[52]។

១៦. ដោយការសំអាងទៅលើវិធាន ៣៥ នៃវិធានផ្ទៃក្នុង និងយុត្តិសាស្ត្រទាក់ទងនឹងបទប្បញ្ញត្តិស្រដៀងគ្នា ដែលអាចអនុវត្តបាននៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ("ICTY") អ.ប.ជ បានពិចារណាថាមាន "*បទដ្ឋានក្នុងការបង្ហាញភស្តុតាងចំនួនបីផ្សេងៗគ្នា* ដែលតម្រូវឱ្យមានការយកចិត្តទុកដាក់ នៅពេលពិចារណាអំពីការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ ដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង"[53]។

> បទដ្ឋានទាំងនេះគឺ (i) មូលហេតុអាចឱ្យជឿបាន (ii) មូលដ្ឋានគ្រប់គ្រាន់ និង (iii) ឱ្យហួសពីវិមតិសង្ស័យ។ បទដ្ឋាននៃការបង្ហាញថាមាន *មូលហេតុអាចឱ្យជឿបាន* ត្រូវបានចែងនៅក្នុងវិធាន ៣៥(២) នៃវិធានផ្ទៃក្នុងដែលផ្តល់នូវចំណាត់ការចំនួនបី នៅពេលដែល "សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះមាន *មូលហេតុអាចឱ្យជឿបាន* ថាបុគ្គលណាមួយអាចបានប្រព្រឹត្តអំពើណាមួយក្នុងចំណោមអំពើទាំងឡាយ" ដែលត្រូវរៀបរាប់នៅក្នុងវិធាន ៣៥(១)នៃវិធានផ្ទៃក្នុង។ បទដ្ឋានដែលតម្រូវឱ្យមាន*មូលដ្ឋានគ្រប់គ្រាន់* ត្រូវបំពេញដើម្បីឱ្យមានការបើកកិច្ចដំណើរការនីតិវិធីចាត់ការបញ្ហានោះភ្លាមៗ ឬបញ្ជូនបញ្ហានោះឱ្យទៅស្ថាប័នមានសមត្ថកិច្ចរបស់ប្រទេសកម្ពុជា ឬរបស់អង្គការសហប្រជាជាតិ។ បទដ្ឋាននៃការបង្ហាញភស្តុតាង*ឱ្យហួសពីវិមតិសង្ស័យ* ត្រូវតែបំពេញ មុននឹងអនុវត្តនូវការដាក់ទណ្ឌកម្មនានាទៅលើបុគ្គលដែលបានរំលោភបំពានលើវិធាន ៣៥(១) នៃវិធានផ្ទៃក្នុង[54]។

យោងតាម អ.ប.ជ "បទដ្ឋានដែលតម្រូវឱ្យមានមូលហេតុអាចឱ្យជឿបាន *គឺជាបទដ្ឋានដែលមានលក្ខណៈស្រាលបំផុត* ហើយនឹងអាចនាំឱ្យមានការស៊ើបសួរពីសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះណាមួយតែប៉ុណ្ណោះ"[55]។

---

[52] វិធាន ៣៥(២) នៃវិធានផ្ទៃក្នុង (មានបញ្ជាក់បន្ថែម)។

[53] សាលដីកាលើកទីពីរ សម្រេចលើសំណើសុំឱ្យកោះហៅសាក្សី កថាខណ្ឌ ៣៦ (មានបញ្ជាក់បន្ថែម)។

[54] *ដូចខាងលើ* កថាខណ្ឌ ៣៦ (មានបញ្ជាក់នៅក្នុងឯកសារដើម)។

[55] សាលដីកាលើកទីពីររបស់ អ.ប.ជ កថាខណ្ឌ ៣៧ (មានបញ្ជាក់បន្ថែម)។ សម្គាល់៖ "ខ្លឹមសារទូលំទូលាយនៃលក្ខខណ្ឌតម្រូវនេះគឺត្រូវបានបញ្ជាក់ដោយការដាក់បញ្ចូលពាក្យថា *អាច* ទៅក្នុងវិធាន ៣៥(២) នៃវិធានផ្ទៃក្នុង។ ការរកឃើញថា មានហេតុផលអាចឱ្យជឿបានមិនតម្រូវឱ្យមានណាមួយ ឬ មិនពាក់ព័ន្ធទៅនឹងសេចក្តីសម្រេចលើអង្គសេចក្តីនៃការចោទប្រកាន់ ឬភាពសង្ស័យនៃការជ្រៀតជ្រែកនោះទេ។ ប៉ុន្តែ ចំពោះការរកឃើញថា មានហេតុផលជាច្រើនឱ្យជឿបានថាបទដ្ឋានត្រូវបានបំពេញ តម្រូវឱ្យ ស.ច.ស ឬអង្គជំនុំជម្រះសន្និដ្ឋានថា មានមូលដ្ឋានជាក់លាក់ ឬមូលហេតុ ដែលជាមូលដ្ឋាននៃជំនឿខ្លួន។

១៧. បទដ្ឋានសំខាន់មួយសម្រាប់ការការពារអនាគតិភាព និងឯករាជ្យភាពរបស់ អ.វ.ត.ក និងដើម្បីធានាបន្ថែមទៀតឱ្យមានការជំនុំជម្រះក្តីដោយយុត្តិធម៌សម្រាប់ជនជាប់ចោទ គឺវិធាន ៣៥ នៃវិធានផ្ទៃក្នុង ដ៏មានសារៈសំខាន់លើសលុប៖

> វិធាន ៣៥ ត្រូវបានដាក់បញ្ចូលទៅក្នុងវិធានផ្ទៃក្នុង ដើម្បីធ្វើជាយន្តការមួយក្នុងការធានាភាពជឿជាក់លើកិច្ចដំណើរការរបស់តុលាការ ទាំងនៅដំណាក់ស៊ើបអង្កេត និងដំណាក់កាលជំនុំជម្រះ។ ភាពជឿជាក់លើកិច្ចដំណើរការនីតិវិធី ត្រូវបានធានាតាមរយៈការអនុវត្តវិធាននេះឱ្យបានត្រឹមត្រូវ នៅពេលដែល ក.ស.ច.ស ឬ អង្គជំនុំជម្រះចាត់ទុកថា សកម្មភាពរបស់បុគ្គលណាម្នាក់បានគំរាមកំហែងដល់កិច្ចការរបស់អង្គជំនុំជម្រះវិសាមញ្ញ។ *ទោះបីជានៅពេលមិនមានផលប៉ះពាល់ដោយផ្ទាល់លើសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ឬសេចក្តីសម្រេចរបស់តុលាការក៏ដោយ* ក៏ការអនុវត្តបទប្បញ្ញត្តិនេះ គឺជាការរារាំងបុគ្គលដទៃដែលអាចត្រូវបានគេមើលឃើញថា អាចជ្រៀតជ្រែកដល់ដំណើរការនីតិវិធី។ វិធីនេះក៏ជំរុញឱ្យមានការជឿទុកចិត្តពីបុគ្គលដែលបានផ្តល់ចម្លើយរួចមកហើយ និងចំពោះបុគ្គលដែលអាចយល់ឃើញថានឹងមកផ្តល់ភស្តុតាង ដោយធ្វើឱ្យបុគ្គលទាំងនេះជឿជាក់ថា ស.ច.ស និង/ឬ *អង្គជំនុំជម្រះ នឹងចាត់វិធានការដោយមិនមានការស្ទាក់ស្ទើរ* ចំពោះបុគ្គលទាំងឡាយណាដែលមានបំណងរារាំង ឬជ្រៀតជ្រែកដល់ការចូលរួមរបស់ពួកគេជាមួយនឹង អ.វ.ត.ក។ ប្រសិនបើអនុវត្តដូច្នេះមែន វានឹងធ្វើឱ្យមានភាពជឿជាក់លើកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ទាំងក្នុងកម្រិតអន្តរជាតិ និងកម្រិតជាតិ[56]។

យោងទៅលើមុខងារការពារ និងការអនុវត្តទូទៅរបស់ខ្លួន[57] អ.ប.ជ បានផ្តល់នូវការបកស្រាយវិធាន ៣៥ ដោយសេរី។

១៨. ស្របជាមួយនឹងបញ្ហានេះដែរ អ.ប.ជ បានទទួលស្គាល់ថា ស្ថាប័នរបស់ អ.វ.ត.ក មានអំណាចចាត់ការតាមឆន្ទានុសិទ្ធិ ដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង នៅពេលមានសំណើសុំពីសំណាក់ភាគីមួយនៃដំណើរការនីតិវិធី៖

---

មូលដ្ឋាន ឬមូលហេតុជាក់លាក់នេះ ត្រូវតែបង្ហាញឱ្យឃើញ ដោយផ្អែកលើការពិនិត្យលើការចោទប្រកាន់ ឬការសង្ស័យដែលការពិនិត្យនេះអាចមានលក្ខណៈជាអត្តនោម័ត"។ *ដូចខាងលើ* កថាខណ្ឌ ៣៧។ *សូមមើល ដូចខាងលើផងដែរ* កថាខណ្ឌ ៣៨ និងកថាខណ្ឌ ៣៩ (ទាក់ទងនឹងមូលហេតុគ្រប់គ្រាន់ និងបទដ្ឋាននានាលើសពីវិមតិសង្ស័យ)។

[56] ឯកសារ **D314/2/7** "សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី និងលោក នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើសុំឱ្យកោះហៅសាក្សី" ចុះថ្ងៃទី ៨ ខែមិថុនា ឆ្នាំ ២០១០ ឯកសារ ERN 00527392–00527420 កថាខណ្ឌ ៣៨ (មានបញ្ជាក់បន្ថែម)។

[57] *កំណត់សម្គាល់*៖ វិធាន ៣៥ ស្ថិតនៅក្រោមចំណងជើង "III. នីតិវិធី ក. បទប្បញ្ញត្តិទូទៅ"។

អង្គបុរេជំនុំជម្រះបានកត់សម្គាល់នូវសេចក្តីសម្រេចមុនរបស់ខ្លួន ដែលបានលើកឡើងថា៖ "វិធាន [៣៥] មិនបានចែងអំពីការផ្តួចផ្តើមកិច្ចស៊ើបសួរ តាមរយៈសំណើសុំរបស់ភាគីនោះទេ។ ផ្ទុយទៅវិញ វិធាននេះចាត់ទុកបញ្ហានេះឱ្យស្ថិតនៅក្រោមឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ"។ ប៉ុន្តែ អង្គជំនុំជម្រះយល់ស្របជាមួយនឹងការលើកឡើងរបស់សហមេធាវីការពារក្តីរបស់លោក នួន ជា ថា៖ "ក.ស.ច.ស មានអំណាចស្របច្បាប់ក្នុងការចាត់វិធានការតាមឆន្ទានុសិទ្ធិ ដោយអនុលោមតាមវិធាន ៣៥ *ដោយមិនគិតពីចរិតលក្ខណៈនៃព័ត៌មានពាក់ព័ន្ធ ដែលបានដាក់មកចំពោះមុខខ្លួននោះទេ*" [58]។

ជំហរនេះបានធ្វើការបញ្ជាក់យ៉ាងត្រឹមត្រូវ អំពីសំណើសុំដោយអនុលោមតាមវិធាន ៣៥ ទៅលើការជ្រៀតជ្រែកដែលបានចោទប្រកាន់ដោយផ្ទាល់ ជាជាងទៅលើបញ្ហានីតិវិធីដែលភស្តុតាងនៃការជ្រៀតជ្រែក ដែលភស្តុតាងនៃការជ្រៀតជ្រែកបែបនេះឈានទៅដល់គោលដៅរបស់អ្នកទទួល (ស.ច.ស ឬអង្គជំនុំជម្រះណាមួយ)។ ការជ្រៀតជ្រែក គឺជាបញ្ហាសំខាន់បំផុត ចំណែកឯបញ្ហានីតិវិធី ដែលជាបញ្ហាបច្ចេកទេស គឺជាបញ្ហាបន្ទាប់បន្សំ។

## ខ. ភាពអាចទទួលយកបាននៃបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចនានា ដែលបានធ្វើឡើងដោយអនុលោមតាមវិធាន ៣៥

១៩. អនុលោមតាមវិធាន ១០៤(៤) "សេចក្តីសម្រេចនានាស្តីពីការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ តាមវិធាន ៣៥(៦)" ត្រូវបើកផ្លូវឱ្យប្តឹងសាទុក្ខភ្លាមៗ[59]។ ភាគីដែលស្នើប្តឹង

[58] សេចក្តីសម្រេចលើសំណើសុំឱ្យកោះហៅសាក្សី កថាខណ្ឌ ៤៣ (មានបញ្ជាក់បន្ថែម)។ *កំណត់សម្គាល់*៖ នៅក្នុងសេចក្តីសម្រេចលើសំណុំរឿង ០០១ អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា ភាគីអាចដាក់សំណើសុំទាំងឡាយបាន ដោយអនុលោមតាមវិធាន ៣៥៖ "ក្នុងខណៈដែលអង្គជំនុំជម្រះសាលាដំបូងមានអំណាចដាក់ទណ្ឌកម្មទៅលើការជ្រៀតជ្រែកណាមួយចូលក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ (ដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង) [...] នាពេលបច្ចុប្បន្ននេះ អង្គជំនុំជម្រះសាលាដំបូង *មិនបានទទួលនូវសំណើបែបនេះទេ*។ សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អ.វ.ត.ក-អ.ជ.ស.ដ ឯកសារលេខ E65/9 "សេចក្តីសម្រេចលើសំណើរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ ដែលសុំឱ្យអង្គជំនុំជម្រះសាលាដំបូងជួយសម្រួលឱ្យមានការផ្សព្វផ្សាយដល់ភាគីនូវរបាយការណ៍របស់ UN-OIOS " ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ២០០៩ ឯកសារ ERN 00378404–00378404 កថាខណ្ឌ ១៧ (មានបញ្ជាក់បន្ថែម)។ សំណួរ៖ តើអង្គជំនុំជម្រះសាលាដំបូងអាច "ទទួល" សំណើសុំដោយអនុលោមតាមវិធាន ៣៥ ដោយរបៀបណាទៅវិញ ប្រសិនបើមិនទទួលសំណើសុំដែលដាក់ដោយភាគីនោះទេ?

[59] វិធាន ១០៤(៤)(ឃ)។ *សូមមើលផងដែរ* វិធាន ៣៥(៦) ("រាល់សេចក្តីសម្រេចដែលធ្វើឡើងក្រោមវិធាននេះ អាចត្រូវប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ ឬប្តឹងសាទុក្ខទៅអង្គជំនុំជម្រះតុលាការកំពូល តាមករណីសមស្រប។ [...] ចំពោះបណ្តឹងសាទុក្ខ

សាទុក្ខចំពោះសេចក្ដីសម្រេចនេះ "ត្រូវដាក់បណ្ដឹងសាទុក្ខភ្លាមៗនេះ ដោយបញ្ជាក់ពីមូលដ្ឋានគាំទ្របណ្ដឹងសាទុក្ខ និងទឡ្ហីករណ៍នានា"[60]។ បណ្ដឹងសាទុក្ខនេះ "ត្រូវបង្ហាញអំពីមូលដ្ឋាន ឬ ខ្លឹមសារនៃសេចក្ដីសម្រេចដែលខ្លួនជំទាស់ដោយយោងលេខទំព័រ និងវាក្យខណ្ឌជាក់លាក់នៃសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង"[61]។ "ក្នុងករណីដែលសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបើកឱ្យមានបណ្ដឹងសាទុក្ខភ្លាមៗ ដូចមានចែងក្នុងវិធាន១០៤ (៤) (ក) និង(ឃ) បណ្ដឹងសាទុក្ខត្រូវធ្វើឡើងក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ ចាប់ពីថ្ងៃប្រកាសសេចក្ដីសម្រេច ឬ ពីថ្ងៃជូនដំណឹងអំពីសេចក្ដីសម្រេចនោះ"[62]។

## គ. បទដ្ឋានទូទៅនៃការពិនិត្យបណ្ដឹងសាទុក្ខឡើងវិញ សម្រាប់បណ្ដឹងសាទុក្ខភ្លាមៗ

២០. "អនុលោមតាម[...] វិធាន ១០៤(១) និង ១០៥(២) បណ្ដឹងសាទុក្ខភ្លាមៗអាចផ្អែកលើមូលដ្ឋានមួយ ឬលើសពីមួយក្នុងចំណោមមូលដ្ឋានបីយ៉ាងដូចខាងក្រោម: កំហុសលើអង្គច្បាប់ ដែលនាំឱ្យមោឃៈសេចក្ដីសម្រេចនោះ។ កំហុសនៃអង្គហេតុដែលនាំឱ្យសេចក្ដីសម្រេចនោះមានភាពមិនយុត្តិធម៌ ឬ ការភ័ន្តច្រឡំដែលស្ដែងចេញពីការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដែលនាំឱ្យប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្ដឹងសាទុក្ខ"[63]។ អង្គជំនុំជម្រះនេះបានបំភ្លឺថា "ទឡ្ហីករណ៍បណ្ដឹងសាទុក្ខដែលមានរៀបរាប់ ក្នុង [...] វិធាន ១០៥(២) នៃវិធានផ្ទៃក្នុង ទាក់ទងនឹងបណ្ដឹង

---

ដែលធ្វើឡើងចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ម្ចាស់បណ្ដឹងសាទុក្ខត្រូវធ្វើឡើងដោយអនុលោមទៅតាមនីតិវិធី និងរយៈពេលកំណត់ដូចមានចែងក្នុងវិធាន ១០៥ អនុវិធាន ២ និងវិធាន ១០៧ អនុវិធាន ១")។

[60] វិធាន ១០៥(២)។

[61] វិធាន ១០៥(៤)។ កំណត់សម្គាល់ បណ្ដឹងសាទុក្ខភ្លាមៗត្រូវ "ដាក់ជូនក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង" និងត្រូវ "ចុះហត្ថលេខាដោយដើមបណ្ដឹងសាទុក្ខ ឬមេធាវីដើមបណ្ដឹងសាទុក្ខ"។ វិធាន ១០៦(២) និង ១០៦(៤) ដោយឡែកពីគ្នា (សេចក្ដីបញ្ជាក់បន្ថែម)។

[62] វិធាន ១០៧(១)។

[63] ឯកសារ លេខ **E-50/2/1/4** អង្គជំនុំជម្រះតុលាការកំពូល ជាសាធារណៈ: "សេចក្ដីសម្រេចស្ដីពីបណ្ដឹងសាទុក្ខភ្លាមៗរបស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំដោះលែងជាបន្ទាន់" ចុះថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ២០១១ ERN 00702255–00702274 ("សេចក្ដីសម្រេចលើសំណើសុំដោះលែង") កថាខណ្ឌ ២៧។

សាទុក្ខភ្លាមៗ ត្រូវតែអាន *ដាច់ចេញពីគ្នា*"[64]។ "សម្រាប់គោលបំណងទាំងអស់នេះ អង្គជំនុំជម្រះតុលាការកំពូលអាចបើកការពិនិត្យលើភស្តុតាង និងស្វែងរកភស្តុតាងថ្មី ដើម្បីធ្វើការសម្រេចលើបញ្ហានេះ" [65]។

## ឃ. សេចក្តីសម្រេចនានាដែលបានបញ្ជាក់សំអាងហេតុ

២១. (ស្មើរតែ) ពិតណាស់ដែលថា ដីកា និងសេចក្តីសម្រេចនានារបស់អង្គជំនុំជម្រះសាលាដំបូងត្រូវតែមានបញ្ជាក់ហេតុផលឲ្យបានគ្រប់គ្រាន់។ យោងតាមច្បាប់យុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិលក្ខខណ្ឌកំណត់បែបនេះ - ដែលជាធាតុផ្សំមួយក្នុងចំណោមធាតុផ្សំនានានៃសិទ្ធិដ៏ទូលំទូលាយក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយយុត្តិធម៌[66] - ប្រើប្រាស់គោលបំណងពីរយ៉ាង: (១) វា "ជួយឲ្យអនុវត្តសិទ្ធិរបស់ជនជាប់ចោទក្នុងការធ្វើបណ្តឹងសាទុក្ខប្រកបដោយអត្ថប្រយោជន៍"[67] និង (២) វា "អនុញ្ញាតឲ្យស្ថាប័នទទួលបណ្តឹងសាទុក្ខបានយល់ និងបានពិនិត្យមើលសំអាងហេតុនានារបស់តុលាការជាន់ទាប ក៏ដូចជាការវាយតម្លៃលើភស្តុតាងរបស់តុលាការជាន់ទាប"[68]។ សេចក្តីសម្រេចដែលបានបញ្ជាក់សំអាងហេតុពិតប្រាកដ គឺជាសេចក្តីសម្រេចមួយដែលក្នុងនោះ សនិទានភាព "អាចឲ្យគេយល់បានយ៉ាងពេញលេញដោយសារសេចក្តីសម្រេចនោះតែម្តង" និងដែល "កំណត់ ... អង្គហេតុពាក់ព័ន្ធនានា និងទឡ្ហីករណ៍ច្បាប់នានាដែល... ត្រូវបាន រកឃើញថា អាចឲ្យជឿបានសម្រាប់ឈានដល់ការធ្វើសេចក្តីសម្រេច" [69]។

---

[64] សេចក្តីសម្រេចលើសំណើសុំដោះលែង កថាខណ្ឌ ២៨។ "ហេតុដូច្នេះ ដើម្បីសំអាងលើទឡ្ហីករណ៍ទីមួយ ឬទីពីរនៃបណ្តឹងសាទុក្ខ (កំហុសឆ្គងនៃអង្គច្បាប់ ឬអង្គហេតុ) ភាគីបណ្តឹងសាទុក្ខ មិនតម្រូវឲ្យបង្ហាញបន្ថែមនូវកំហុសឆ្គងដែលស្តែងចេញពីការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបណ្តាលឲ្យមានផលប៉ះពាល់ដល់សិទ្ធិរបស់ខ្លួនឡើយ"។ *ដូចខាងលើ*។

[65] វិធាន ១០៤(១)។

[66] *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Momir Nikolic សំណុំរឿង IT-02-60/1-A "សាលដីកាលើបណ្តឹងសាទុក្ខស្តីពីការផ្តន្ទាទោស" ចុះថ្ងៃទី ៨ ខែ មីនា ឆ្នាំ ២០០៦ កថាខណ្ឌ ៩៦។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Dragoljub Kunarac* សំណុំរឿង IT-96-23/1-A "សាលដីកា" ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០២ កថាខណ្ឌ ៤១។

[67] រឿងក្តី *Kunarac* កថាខណ្ឌ ៤១។

[68] ដូចខាងលើ។

[69] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Thomas Lubanga Dyilo* សំណុំរឿង ICC-01/04-01/06 (OA 6) "សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក Thomas Lubanga Dyilo ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ I ដែលមានចំណងជើងថា "សេចក្តីសម្រេចលើកទីពីរលើសំណើរបស់រដ្ឋអាជ្ញា និងសំណើដែលបានកែប្រែសុំកែតម្រូវតាមវិធាន ៨១" ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៦ កថាខណ្ឌ ៣៣។

## ង. ភស្តុតាងបរិបទ និងបែបបទ

២២. នៅក្នុងការវាយតម្លៃលើការចោទប្រកាន់នានាលើអង្គសេចក្តីប្រឆាំងនឹងជនជាប់ចោទ អង្គជំនុំជម្រះក្តីទាំងឡាយមានសេរីភាពក្នុងការឱ្យតម្លៃជាភស្តុតាងចំពោះភស្តុតាងនៃព្រឹត្តិការណ៍នានា ដែលស្ថិតនៅក្រៅយុត្តាធិការតាមពេលវេលារបស់តុលាការ នៅពេលដែលភស្តុតាងបែបនេះមានបំណងមួយ *ក្នុងចំណោមបំណងនានា* "បំភ្លឺបរិបទដែលបានផ្តល់ឱ្យ" ឬ "បង្ហាញពីបែបបទដែលបានគិតទុកជាមុននៃទង្វើ"[70]។ ដោយ កម្រិតស្មើគ្នា តាមសទិសភាព តុលាការនានាអាចធ្វើការវាយតម្លៃបានដោយសេរីលើភស្តុតាង ដែលមានលក្ខណៈស្រដៀងគ្នា - ដែលជាភស្តុតាងតាមបរិបទ និង/ឬបែបបទ - នៅក្នុងការសម្រេចលើបញ្ហា ថាតើមានការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ ដែរឬទេ។ ពុំមានសំអាងហេតុជាគោលការណ៍ដើម្បីអនុវត្តវិធីសាស្ត្រមួយ ដែលមានលក្ខណៈតឹងរ៉ឹងជាង វិធីសាស្ត្រដែលបានលើកឡើងនៅក្នុងវិធាន ៨៧(១) នោះទេ "លើកលែងតែមានបទប្បញ្ញត្តិផ្សេងក្នុងវិធានផ្ទៃក្នុងនេះ រាល់ភស្តុតាងទាំងអស់ត្រូវតែទទួលយក" ដើម្បីធ្វើការវាយតម្លៃលើភស្តុតាងដែលបាន ផ្តល់ឱ្យដើម្បីគាំទ្រសំណើដែលបានធ្វើឡើង ដោយអនុលោមតាមវិធាន ៣៥។

## IV. ឧឡារិករណ៍

## ក. បណ្តឹងសាទុក្ខអាចទទួលយកបាន

២៣. ដោយហេតុថា សេចក្តីសម្រេចដែលរងការជំទាស់ចាត់ទុក (មួយផ្នែក) ជាការសម្រេច "លើការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ ក្រោមវិធាន ៣៥(៦)" ដីកាដែលរងការជំទាស់ត្រូវបើកផ្លូវឱ្យប្តឹងសាទុក្ខភ្លាមៗ[71]។ លើសពីនេះទៀត សេចក្តីសន្និដ្ឋានពេលនេះ (ក) បញ្ជាក់

---

[70] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Nahimana et al សំណុំរឿង ICTR-99-52-A "សាលដីកា" ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧ កថាខណ្ឌ ៣១៥។ *សូមមើលផងដែរ ឧទាហរណ៍* FRE 406 ("ភស្តុតាងនៃទម្លាប់របស់មនុស្សម្នាក់ ឬនៃទម្លាប់អនុវត្តដដែលៗរបស់អង្គការមួយ បញ្ហាថាតើបានបញ្ជាក់ដែរឬទេ និងការមិនយកចិត្តទុកដាក់លើវត្តមានរបស់សាក្សីដែលឃើញផ្ទាល់ភ្នែក មានការពាក់ព័ន្ធទៅនឹងការបង្ហាញភស្តុតាងថា ការប្រព្រឹត្តរបស់មនុស្សឬអង្គការនៅឱកាសពិសេស គឺស្របតាមទម្លាប់ ឬការអនុវត្តដដែលៗ")។

[71] *សូមមើល* កថាខណ្ឌ ១៩ ខាងលើ។ ទោះបីជាវាមានការពាក់ព័ន្ធជាមួយនឹងបញ្ហាទាក់ទិនមួយចំនួនក៏ដោយ សេចក្តីសម្រេចដែលរងការជំទាស់ពិតជាបដិសេធសំណើសុំអនុលោមតាមវិធាន ៣៥ យ៉ាងច្បាស់លាស់។

ពីមូលដ្ឋានគាំទ្របណ្ដឹងសាទុក្ខ និងទឡ្ហីករណ៍នានា"[72] (ខ) "បង្ហាញអំពីមូលដ្ឋាន ឬខ្លឹមសារនៃសេចក្ដីសម្រេចដែលខ្លួនជំទាស់ ដោយយោងលេខទំព័រ និងវាក្យខណ្ឌជាក់លាក់នៃសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង"[73] និង (គ) បាន "ធ្វើឡើងក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ ចាប់ពីថ្ងៃប្រកាសសេចក្ដីសម្រេច ឬ ពីថ្ងៃជូនដំណឹងអំពីសេចក្ដីសម្រេចនោះ"[74]។ ហេតុនេះ បណ្ដឹងសាទុក្ខអាចទទួលយកបានផង និងទាន់ពេលវេលាផង។

**ខ. សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងមិនបំពេញតួនាទី ដោយអនុលោមតាមវិធាន ៣៥ មិនអាចការពារបានទេ ដោយសារមូលហេតុមួយចំនួន**

***១. អង្គជំនុំជម្រះសាលាដំបូងមិនយកចិត្តទុកដាក់ដល់សេចក្ដីអះអាងនានាពាក់ព័ន្ធផ្ទាល់ទៅនឹងសំណុំរឿង ០០២ និងមិនបានផ្ដល់នូវមូលហេតុណាមួយសម្រាប់ការបដិសេធនេះទេ***

២៤. សំណើសុំអនុលោមតាមវិធាន ៣៥ បានលើកឡើងជាក់លាក់អំពីការជ្រៀតជ្រែករបស់រដ្ឋាភិបាលទៅក្នុង សំណុំរឿង ០០២ ពោលគឺៈ កិច្ចប្រឹងប្រែងរួមគ្នារបស់រាជរដ្ឋាភិបាលកម្ពុជា (ក) ធ្វើឱ្យការប៉ុនប៉ងរបស់សហចៅក្រមស៊ើបអង្កេតក្នុងការទទួលបានសក្ខីកម្មពីសម្ដេចឪ នរោត្ដម សីហនុ មិនបានសម្រេច[75] និង (ខ) រារាំងការអនុវត្តការកោះអញ្ជើញមន្ត្រីក្នុងជួររដ្ឋាភិបាលដែលបានចេញយ៉ាងត្រឹមត្រូវ[76]។ ជាជាងការលើកឡើងអំពីសេចក្ដីអះអាងលម្អិត និងដែលត្រូវបានជជែកការពារយ៉ាងច្បាស់លាស់ទាំងអស់នេះ សេចក្ដីសម្រេចដែលរងការជំទាស់មិនបានយកចិត្តទុកដាក់ទៅលើសេចក្ដីអះអាងទាំងនេះទេ។ ដោយហេតុថា អង្គជំនុំជម្រះសាលាដំបូងមានកាតព្វកិច្ចដោះស្រាយពាក្យសុំរបស់ភាគី តាមរយៈការចេញសេចក្ដីសម្រេចដែលត្រូវបានបញ្ជាក់សំអាងហេតុ[77] ការធ្វេសប្រហែសមិនបានធ្វើដូច្នេះគឺជាការភ័ន្តច្រឡំអង្គច្បាប់ - *តាមអង្គហេតុពិត* (*ipso facto*)។ មិនគ្រាន់តែសិទ្ធិក្នុងការធ្វើបណ្ដឹងសាទុក្ខរបស់ នួន ជា ត្រូវបានរារាំងតាមរយៈការបដិសេធនេះប៉ុណ្ណោះទេ អង្គជំនុំជម្រះនេះពុំមានតួនាទី "ស្វែងយល់ និងពិនិត្យឡើងវិញលើសំអាងហេតុនានារបស់ [អង្គជំនុំជម្រះសាលាដំបូង] ក៏ដូចជាការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងចំពោះ

[72] វិធាន ១០៥(២)។

[73] វិធាន ១០៥(៤)។

[74] វិធាន ១០៧(១)។

[75] *សូមមើល* សំណើសុំអនុលោមតាមវិធាន ៣៥ កថាខណ្ឌ ៣(ក)។

[76] *ដូចខាងលើ* កថាខណ្ឌ ៣(ខ) ដល់ (គ)។

[77] *សូមមើល* កថាខណ្ឌ ២១ ខាងលើ។

ភស្តុតាងនោះទេ"[78]។ សិទ្ធិរបស់ នួន ជា ត្រូវបានប៉ះពាល់ ពាក់ព័ន្ធនឹងការអះអាងនៅក្នុងសំណុំរឿង ០០២ អង្គជំនុំជម្រះសាលាដំបូង*ពុំ*បានធ្វើសំអាងហេតុ ឬពុំបានចូលរួម នៅក្នុងការវាយតម្លៃ*ណាមួយ*។

### *២ អង្គជំនុំជម្រះសាលាដំបូងមានកំហុសនៅក្នុងការលើកឡើងថា អង្គជំនុំជម្រះ អាចបំពេញតួនាទីស្របតែតាមវិធាន ៣៥ ប៉ុណ្ណោះ ទាក់ទងនឹងសេចក្តីអះអាង នានាដែលពាក់ព័ន្ធផ្ទាល់ទៅនឹងបញ្ហាអង្គហេតុទាំងឡាយដែលអង្គជំនុំជម្រះបានទទួល*

២៥. ទាំងអត្ថបទនៃវិធាន ៣៥ ទាំងសនិទានភាពដែលជាដើមចមនៃវិធាន ៣៥ ពុំបានបង្ខំឱ្យមានការអនុវត្តនូវវិធីសាស្ត្រដែលមានលក្ខណៈចង្អៀត ដូចវិធីសាស្ត្រដែលត្រូវបានអនុម័ត ដោយអង្គជំនុំជម្រះសាលាដំបូងនោះទេ។ ផ្ទុយទៅវិញ ភាសាទូលំទូលាយនៃបទប្បញ្ញត្តិ ក៏ដូចជាអាណត្តិច្បាស់លាស់នៃបទប្បញ្ញត្តិ គាំទ្រជាប្រយោជន៍ឱ្យមានការបកស្រាយកាន់តែទូលំទូលាយ អំពីអំណាចដែលបានផ្តល់ឱ្យ ក.ស.ច.ស និងអង្គជំនុំជម្រះផ្សេងៗ នៅពេលលើកឡើងពីដំណើរនៃការរារាំងភាពយុត្តិធម៌។

២៦. វិធាន ៣៥(១) ផ្តល់ឱ្យ "អ.វ.ត.ក - ដែលជាស្ថាប័នខ្លួនឯង- នូវអំណាចក្នុងការ "ដាក់ទណ្ឌកម្ម ឬបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ចនូវជនណាម្នាក់ ដែលជ្រៀតជ្រែកដោយចេតនាពិតប្រាកដក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ"។ បទប្បញ្ញត្តិត្រូវបានរៀបចំឡើងដើម្បីប្រើប្រាស់ "ដើម្បីធ្វើជាយន្តការមួយក្នុងការធានាភាពជឿជាក់លើកិច្ចដំណើរការរបស់តុលាការ ទាំងដំណាក់កាលស៊ើបអង្កេត និងដំណាក់កាលជំនុំជម្រះ"[79]។ បទប្បញ្ញត្តិមិនត្រូវអនុវត្ត ដោយគ្រាន់តែផ្អែកលើខ្លឹមសារនៃបទប្បញ្ញត្តិខ្លួនឯង ឬគោលបំណងដែលចែងថា " កិច្ចស៊ើបសួរដោយអនុលោមតាមវិធាន ៣៥ អាចនឹង[...] ត្រូវបានអនុវត្តដោយប្រសិទ្ធភាព ដោយស្ថាប័នតុលាការដែលទទួលសំណុំរឿងនេះ" [80] ឡើយ។ សេចក្តីសម្រេចដែលរងការជំទាស់ ក៏មិនបានពន្យល់ថា អង្គជំនុំជម្រះសាលាដំបូងបានសម្រេចសន្និដ្ឋានយ៉ាងដូច្នេះដោយវិធីណានោះដែរ។

---

[78] *ដូចខាងលើ*។

[79] សាលដីកាលើសំណើសុំកោះហៅសាក្សី កថាខណ្ឌ ៣៨។

[80] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ២១។

២៧. វិធីសាស្ត្រត្រឹមត្រូវ ដែលជាវិធីសាស្ត្រដែលអង្គជំនុំជម្រះសាលាដំបូងគួរតែបានយកមកអនុវត្ត ចំពោះករណីនេះ ត្រូវបានបញ្ជាក់កាលពីមុនដោយអង្គបុរេជំនុំជម្រះ និងត្រូវបានលើកឡើងដដែលៗ ជាថ្មីម្តងទៀតនាពេលនេះ:

> ភាពជឿជាក់លើកិច្ចដំណើរការនីតិវិធីត្រូវបានធានា តាមរយៈការអនុវត្តវិធាននេះឱ្យបានត្រឹមត្រូវ នៅពេលដែល ស.ច.ស ឬអង្គជំនុំជម្រះចាត់ទុកថា សកម្មភាពរបស់បុគ្គលណាម្នាក់ បានគំរាមកំហែងដល់កិច្ចការរបស់អង្គជំនុំជម្រះវិសាមញ្ញ។ ទោះបីជានៅពេលមិនមានផលប៉ះពាល់ដោយផ្ទាល់លើសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ឬសេចក្តីសម្រេចរបស់តុលាការក៏ដោយ ការអនុវត្តបទប្បញ្ញត្តិនេះ គឺជាយន្តការរារាំងបុគ្គលដទៃ ដែលអាចត្រូវបានគេមើលឃើញថា អាចជ្រៀតជ្រែកដល់ដំណើរការនីតិវិធី។ វិធាននេះក៏ជំរុញឱ្យមានការជឿទុកចិត្តពីបុគ្គលដែលបានផ្តល់ចម្លើយរួចហើយ និងចំពោះបុគ្គលដែលអាចយល់ឃើញថា នឹងមកផ្តល់ភស្តុតាងដោយធ្វើឱ្យបុគ្គលទាំងនេះជឿជាក់ថា ស.ស.ច និង/ឬ អង្គជំនុំជម្រះនឹងចាត់វិធានការដោយមិនមានការស្ទាក់ស្ទើរចំពោះបុគ្គលទាំងឡាយណាដែលមានបំណងរារាំង ឬជ្រៀតជ្រែកការចូលរួមរបស់ពួកគេជាមួយនឹង អ.វ.ត.ក។ ប្រសិនបើអនុវត្តដូច្នេះមែន វានឹងធ្វើឱ្យមានភាពជឿជាក់លើកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ទាំងក្នុងកម្រិតអន្តរជាតិ និងកម្រិតជាតិ[81]។

សរុបមក មានតែ "ការអនុវត្តដោយការពិចារណាយ៉ាងហ្មត់ចត់" នៃវិធាន ៣៥ (ពោលគឺការអនុវត្តដោយមានសុភវិនិច្ឆ័យ) ជាជាងការបកស្រាយបែបទម្រង់និយមដែលជ្រើសរើសដោយអង្គជំនុំជម្រះសាលាដំបូងប៉ុណ្ណោះ នឹងធានាការបង្កើនដោយប្រសិទ្ធភាពនូវកម្មវត្ថុសំខាន់ៗដែលវិធានផ្ទៃក្នុងត្រូវបានរៀបចំឡើងដើម្បីសម្រេចឱ្យបាន។

២៨. វិធីវិទ្យាដែលមានលក្ខណៈនីត្យានុកូលពេក (ទីបំផុត ល្អតែសំបកក្រៅ) ដែលត្រូវបានបង្ហាញតាមរយៈអង្គជំនុំជម្រះសាលាដំបូងត្រង់ចំណុចនេះ ប្រហែលជាការភ័ន្តច្រឡំចម្បងនៅក្នុងសេចក្តីសម្រេចដែលរងការជំទាស់។ មូលហេតុនេះគឺដោយសារតែការបញ្ជាក់ហេតុផលនេះត្រូវបាន "ផ្អែកលើលទ្ធផល" ក្នុងន័យថា ការបញ្ជាក់ហេតុផលនេះត្រូវបានរៀបចំឡើង ដើម្បីធ្វើឱ្យសម្រេចបាននូវលទ្ធផលដែលបានកំណត់ទុកជាមុន - នៅក្នុងករណីនេះ គឺការគេចចេញពីសកម្មភាពការពារ (និងអាចជាសកម្មភាពដាក់ទណ្ឌកម្ម)។ លើសពីភាពមិនត្រឹមត្រូវតាមផ្លូវច្បាប់ ប្រភេទនៃការវិភាគនេះបង្កើតយ៉ាងច្បាស់នូវប្រភេទនៃការគេចចេញពីការទទួលខុសត្រូវ (ដែលជាអ្វីដែល

---

[81] សាលដីកាលើសំណើសុំកោះហៅសាក្សី កថាខណ្ឌ ៣៨ (សេចក្តីបញ្ជាក់បន្ថែម)។

មេធាវីការពារក្តីបានប្រើពាក្យកាលពីមុនថា "ការទម្លាក់ការទទួលខុសត្រូវតាមផ្លូវតុលាការទៅឱ្យអ្នកផ្សេង"[82]) ដែលបានធ្វើឱ្យមានការខឹងសម្បារក្នុងចំណោមអ្នករិះគន់ ដែលបានលើកឡើងខាងដើមយ៉ាងខ្លាំង។

២៩. គេអាចពង្រីកមូលហេតុបន្ថែម ដោយការលើកឧទាហរណ៍ថា អង្គជំនុំជម្រះនេះអាច (ឬគួរតែ) ចាប់ផ្តើមអនុវត្តកិច្ចដំណើរការតាមវិធាន ៣៥ ពាក់ព័ន្ធនឹងសំណុំរឿង ០០២ ដោយមិនបាច់ផ្តល់ឱកាសឱ្យអង្គជំនុំជម្រះសាលាដំបូងបំពេញតួនាទីជាមុនឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ ពុំមានឧបសគ្គផ្លូវច្បាប់ ដែលនឹងរារាំងមិនឱ្យអង្គជំនុំជម្រះសាលាដំបូងសម្រេចលើ ការជ្រៀតជ្រែកណាមួយ*ដែលបានកើតឡើងនៅក្នុងអំឡុងពេលស៊ើបសួរ* នោះទេ - ប្រសិនបើការជ្រៀតជ្រែកបែបនេះ: (ក)មានលក្ខណៈច្បាស់លាស់ ជាលើកដំបូងនៅក្នុងដំណាក់កាលជំនុំជម្រះ ឬ (ខ) ដូចនៅក្នុងករណីពេលនេះ មិនត្រូវបានអើពើដោយខុសឆ្គងដោយ ក.ស.ច.ស និង/ឬ អង្គបុរេជំនុំជម្រះ។ ការលើកឡើងរបស់អង្គជំនុំជម្រះសាលាដំបូងថា សេចក្តីអះអាងនានាដែលបានលើកឡើងនៅពេលនេះ គួរត្រូវបានដោះស្រាយយ៉ាងត្រឹមត្រូវដោយ "ស.ច.ស នៅដំណាក់កាលដំបូង និងអង្គបុរេជំនុំជម្រះ នៅពេលមានបណ្តឹងឧទ្ធរណ៍" ជាការលើកឡើង ដោយខ្វះការពិចារណាផ្នែកខ្លះ។ ពាក់ព័ន្ធនឹងគោលជំហរកាលពីមុនរបស់ ក.ស.ច.ស លើបញ្ហានានា ដែលបានលើកឡើងនៅក្នុងសំណើសុំអនុលោមតាមវិធាន ៣៥ កុំថាឡើយអង្គហេតុដែលថា សហចៅក្រមស៊ើបអង្កេតទាំងពីរបានជាប់សង្ស័យថា បានជំរុញឱ្យមានការជ្រៀតជ្រែកផ្នែកនយោបាយ ដែលបង្កើតបានជាចំណុចសំខាន់នៃសេចក្តីអះអាងរបស់មេធាវីការពារក្តី ដំណើរការប្រព្រឹត្តទៅដែលបានលើកឡើងដោយអង្គជំនុំជម្រះសាលាដំបូង នឹងមានន័យស្មើនឹងការអនុវត្តដោយគ្មានខ្លឹមសារ។ ដូចដែលចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះបានកត់សម្គាល់ឃើញ ក.ស.ច.ស តាមវិជ្ជាជីវៈ មិនសក្តិសមនឹង "ដឹកនាំកិច្ចស៊ើបសួរទៅលើ*ការចោទប្រកាន់ពីការជ្រៀតជ្រែកទាំងអស់នេះទេ*"[83]។

៣០. ជាចុងក្រោយ ពុំមានចំណុចណាមួយនៅក្នុងវិធាន ៣៥ និងដូចដែលបានកត់សម្គាល់ខាងលើ ក៏ដូចជានៅក្នុងស្មារតីនៃការអនុវត្តវិធាន ៣៥ - ដែលតម្រូវឱ្យមានការបង្ហាញពី *ព្យសនកម្មជាក់ស្តែង*

---

[82] *សូមមើល ឧទាហរណ៍* ឯកសារ No **D-314/2/4** "បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ ក.ស.ច.ស សម្រេចអំពីសំណើរបស់ជនត្រូវចោទ នួន ជា និងជនត្រូវចោទ អៀង សារី សុំឱ្យកោះអញ្ជើញសាក្សី" ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១០ ERN 00484112–00484130។

[83] មតិយោបល់ជំទាស់ កថាខណ្ឌ ៨ (សេចក្តីបញ្ជាក់បន្ថែម)។

ចំពោះជនជាប់ចោទ ឬ *ផលប៉ះពាល់ជាក់ស្ដែង* ណាមួយទៅលើកិច្ចដំណើរការនីតិវិធីឡើយ។ សំអាងហេតុសម្រាប់លក្ខខណ្ឌកំណត់នេះមានភាពច្បាស់លាស់: ប្រភេទនៃការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលដូចដែលបានពណ៌នានៅក្នុងវិធាន ៣៥(១) គឺជាការរំលោភបំពានលើស្ថាប័នដែលប៉ះពាល់លើសុចរិតភាពរបស់តុលាការ។ ជាបញ្ហានៃគោលការណ៍ ឥរិយាបថបែបនេះមិនអាចអត់ឱនឱ្យបានទេ ដោយមិនចាំបាច់ថាមាន ឬគ្មានផលប៉ះពាល់ជាក់លាក់ណាមួយលើជនជាប់ចោទ ឬកិច្ចដំណើរការនីតិវិធីនោះឡើយ។ ហេតុនេះ សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការបដិសេធសំណើសុំអនុលោមតាមវិធាន ៣៥ មានកំហុសដូចគ្នា នៅពេលសេចក្ដីសម្រេចនេះ "បានកំណត់*ដោយសន្មត*ថា គ្មានផលប៉ះពាល់ជាក់ស្ដែងនៃការចោទប្រកាន់ទាំងអស់នេះអំពីភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះនៅក្នុងសំណុំរឿង ០០២ (ដែលអង្គជំនុំជម្រះ សាលាដំបូងបានទទួល) នោះទេ"[84] ។

៣១. ការខកខានទាំងអស់នេះចាត់ទុកថាជា "កំហុសលើអង្គច្បាប់ដែលនាំឱ្យមោឃៈ សេចក្ដីសម្រេចនោះ"[85]។

### *៣. អង្គជំនុំជម្រះសាលាដំបូងបានបដិសេធចោលសំណើសុំតាមវិធាន ៣៥ ដោយភ័ន្តច្រឡំ ដោយយល់ខុសពីសេចក្ដីអះអាងអង្គហេតុនានាពាក់ព័ន្ធទៅនឹងសំណុំរឿង ០០៣ និង ០០៤*

៣២. ដោយមិនយកចិត្តទុកដាក់លើសេចក្ដីអះអាងរបស់មេធាវីការពារក្ដីពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២ (ដូចដែលបានពិភាក្សាខាងលើ)[86] និងដោយខកខានមិនបានវិនិច្ឆ័យតម្លៃជាភស្តុតាងសមស្របនៃការចោទប្រកាន់នានាពាក់ព័ន្ធនឹងសំណុំរឿង ០០៣ និង ០០៤ អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តនូវ "ការភ័ន្តច្រឡំដែលស្ដែងចេញពីការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដែលនាំឱ្យប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្ដឹងសាទុក្ខ"[87]។ សម្រាប់ប្រយោជន៍នៃទឡ្ហីករណ៍ ដោយសន្មតថា មេធាវីការពារក្ដីត្រូវបានតម្រូវឱ្យបង្ហាញព្យសនកម្មជាក់ស្ដែងទៅលើសិទ្ធិណាមួយក្នុងចំណោមសិទ្ធិនានារបស់ នួន ជា និង/ឬ ចំណងទាក់ទងជាក់ស្ដែងទៅនឹងសំណុំរឿង ០០២

---

[84] សេចក្ដីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ២១។

[85] សេចក្ដីសម្រេចលើសំណើសុំដោះលែង កថាខណ្ឌ ២៧។

[86] *សូមមើល* កថាខណ្ឌ ២៤ *ខាងលើ* (ករណីដែលមេធាវីការពារក្ដីលើកឡើងថា ការខកខាននេះក៏ចាត់ទុកជាការភ័ន្តច្រឡំអង្គច្បាប់)។

[87] សេចក្ដីសម្រេចលើសំណើសុំដោះលែង កថាខណ្ឌ ២៧។

(បទដ្ឋានភ័ន្តច្រឡំនៃសេចក្តីសម្រេចដែលរងការជំទាស់) អង្គជំនុំជម្រះសាលាដំបូងបានដាកចេញពីភារកិច្ចរបស់ខ្លួន ដើម្បីធានាថា លទ្ធផលបែបនេះនឹងមិនអាចកើតមានឡើយ។ ទោះបីជាយោងយ៉ាងពិស្តារលើបញ្ហានានាដែលប៉ះពាល់ដល់រឿងក្តីនេះក៏ដោយ អង្គជំនុំជម្រះសាលាដំបូងជ្រើសរើសធ្វើការយកចិត្តទុកដាក់តែលើ "ការចោទប្រកាន់អំពីការជ្រៀតជ្រែកទៅក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ ឬ ការជ្រៀតជ្រែកខាងនយោបាយនៅក្នុងសំណុំរឿងលេខ ០០៣ និង ០០៤" ប៉ុណ្ណោះ[88]។ ការយកចិត្តទុកដាក់ដោយការភ័ន្តច្រឡំបែបនេះបានធ្វើឲ្យសំណើសុំតាមវិធាន ៣៥ លែងមានទម្ងន់ជាភស្តុតាង។

៣៣. នៅក្នុងអង្គហេតុជាក់ស្តែង មេធាវីការពារក្តីបានកំណត់បង្ហាញយ៉ាងច្បាស់លាស់អំពីដំណើរនៃការជ្រៀតជ្រែករបស់រដ្ឋាភិបាលដែលបានប៉ះពាល់ផ្ទាល់លើសំណុំរឿង ០០២។ បើកុំតែមានការជ្រៀតជ្រែករបស់រាជរដ្ឋាភិបាលយ៉ាងបើកចំហ ម្ល៉េះសមពេលនេះ សំណុំរឿងមានចម្លើយសាក្សី (ដែលអាចជាការដោះបន្ទុក) របស់សម្តេចឪ នរោត្តម សីហនុ មន្ត្រីនៅក្នុងជួររដ្ឋាភិបាលទាំង ៦ រូប និងអាចអ្នកដទៃទៀត។ បច្ចុប្បន្ននេះ គេមិនបានដឹងថាតើសុចរិតភាពនៃសំណុំរឿងត្រូវរងការប៉ះពាល់បន្ថែមទៀត តាមរយៈទម្រង់នានា ដែលបង្ហាញឲ្យឃើញតិចតួចអំពីការរារាំងរបស់រដ្ឋាភិបាល (ប្រហែលជាត្រូវបានអនុវត្តដោយបុគ្គលិក អ.វ.ត.ក ដែល ពាក់ព័ន្ធនឹងរឿងអាស្រូវអំពើពុករលួយ)[89]។ ជាការពិត ការបញ្ចេញឲ្យឃើញនូវសកម្មភាព បែបនេះគឺជាគោលបំណងមួយក្នុងចំណោមគោលបំណងនានានៃសំណើសុំតាមវិធាន ៣៥។ នៅក្នុងការបដិសេធសំណើសុំនោះ ចៅក្រមទាំងឡាយត្រូវតែពិនិត្យភស្តុតាងនានា ដែលពាក់ព័ន្ធទៅ នឹងសំណុំរឿង ០០៣ និង ០០៤ - *រួមជាមួយនឹងសេចក្តីអះអាងពីសំណុំរឿង ០០២ ដែលត្រូវបានជជែកការពារយ៉ាងច្បាស់លាស់* - នៅពេលពាក់ព័ន្ធទៅនឹងការបំភ្លឺពីបរិបទដែលមានអធិកភាព និងក្នុងការបង្ហាញពីលំនាំដែលបានគិតទុកជាមុននៃការប្រព្រឹត្តរបស់រាជរដ្ឋាភិបាល[90]។ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងបានធ្វើដូច្នេះ សំអាងហេតុនៃការជ្រៀតជ្រែក *តាមការយល់ឃើញបឋម* នឹងមិនអាចគេចផុតឡើយ។ ការវិភាគដែលបានបង្ហាញនៅក្នុងសេចក្តីសម្រេចដែលរងការជំទាស់ បង្ហាញនូវការពង្វាងដោយគិតទុកជាមុននៅក្នុងការបដិសេធមិនធ្វើការពិចារណាលើការចោទប្រកាន់ ជាក់លាក់នានាអំពីការជ្រៀតជ្រែក

---

[88] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ២១។

[89] *សូមមើល* កថាខណ្ឌ ៣(ក) *ខាងលើ*។

[90] *សូមមើល* កថាខណ្ឌ ២២ *ខាងលើ*។

ដែលត្រូវបានជជែករកខុសត្រូវដោយមេធាវីការពារក្តី និងនៅក្នុងការខកខានមិនបានឱ្យតម្លៃលើលក្ខណៈប្រែប្រួល និងកម្រិតនៃភាពពាក់ព័ន្ធរបស់ភស្តុតាងទាំងអស់ដែលបានដាក់ជូន។

៣៤. ការពិនិត្យឡើងវិញឱ្យបានលម្អិតទៅលើកំណត់ហេតុជាក់ស្តែងទាំងអស់ ដែលត្រូវបានបង្ហាញដោយមេធាវីការពារក្តី - រួមទាំងសម្ភារៈដែលត្រូវបានលើកឡើងយ៉ាងជាក់លាក់ជាឯកសារយោង[91] - នឹងនាំឱ្យ "ចៅក្រមជំនុំជម្រះនៃអង្គហេតុដែលមានសុភវិនិច្ឆ័យ"[92] ធ្វើការសន្និដ្ឋានថា មាន "មូលហេតុដែលនាំឱ្យជឿបានថា សមាជិកម្នាក់ ឬច្រើននាក់នៃរាជរដ្ឋាភិបាលកម្ពុជាបាន ជ្រៀតជ្រែកទៅលើសាក្សីនានាដោយបានដឹងជាមុន និងដោយចេតនា"[93]។ ដូចដែលបានកត់ សម្គាល់ដោយចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ សំអាងហេតុនេះមានលក្ខណៈគ្រប់គ្រាន់ ក្នុងការប្រើប្រាស់នូវការស៊ើបអង្កេតបឋមមួយ ស្របតាមបទដ្ឋានស្តីពីមូលហេតុដែលនាំឱ្យជឿបាន នៃវិធាន ៣៥[94] - ដែលជា "បទដ្ឋានដែលមានលក្ខណៈស្រាលបំផុត"[95]។ លើសពីនេះទៀត ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងបានវាយតម្លៃលើដំណើរជាក់ស្តែង នៃការជ្រៀតជ្រែកចូលក្នុងសំណុំរឿង ០០២ ប្រឆាំងនឹងបរិបទដែលទូលំទូលាយជាង ដែលបានផ្តល់ឱ្យតាមរយៈ សេចក្តីអះអាងនានាអំពីការជ្រៀតជ្រែកចូលក្នុងសំណុំរឿង ០០៣ និង ០០៤ ទម្រង់នៃការជ្រៀតជ្រែករបស់រាជរដ្ឋាភិបាលនឹងប្រែក្លាយជាការជ្រៀតជ្រែកពិតប្រាកដ។ ទោះបីជាអង្គជំនុំជម្រះសាលាដំបូងបានបង្ហាញពីទំនោរប្រើប្រាស់ "វិធីសាស្ត្រដែលមិនមានលក្ខណៈជាប្រព័ន្ធ (និងមិនត្រូវបានអភិវឌ្ឍឱ្យបានពេញលេញ)" ចំពោះបញ្ហាគតិយុត្តិនានា[96] ការវាយតម្លៃអំពីអង្គហេតុនានាដោយវិធីដាច់ដោយឡែក នឹងជាញឹកញាប់នាំឱ្យទទួលបានលទ្ធផលដែលមានកំហុស - ដូចនៅក្នុងករណីពេលនេះដែរ។

***៤. អង្គជំនុំជម្រះសាលាដំបូងមានការភ័ន្តច្រឡំនៅក្នុងការលើកឡើងថា ភាគីនានា មិនអាចផ្តួចផ្តើមកិច្ចដំណើរការនីតិវិធីតាមវិធាន ៣៥ តាមញត្តិផ្ទាល់ខ្លួននោះទេ***

---

[91] សំណើសុំតាមវិធាន ៣៥ កថាខណ្ឌ ២ ដល់ ១៣។

[92] មតិយោបល់ជំទាស់ កថាខណ្ឌ ៦។

[93] *ដូចខាងលើ*។

[94] *ដូចខាងលើ*។

[95] សេចក្តីសម្រេចលើកទីពីររបស់ អ.ប.ជ កថាខណ្ឌ ៣៧។

[96] *សូមមើល ឧទាហរណ៍* ឯកសារ No **E-93/9** "សំណើសុំបន្ថែមសាក្សី និងបន្តសវនាការបឋម" ចុះថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ២០១១ ERN 00711970–00711975។

៣៥. ផ្អែកតាមសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ឆ្នាំ ២០០៩ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ឃើញថា "វិធាន ៣៥ មិនបានចែងអំពីការផ្តួចផ្តើមបំពេញកិច្ចស៊ើបសួរតាមការស្នើសុំរបស់ភាគី"[97]។ ទោះបីជាយ៉ាងណាក៏ដោយ ក្រោយមកទៀត អង្គបុរេជំនុំជម្រះបានកែប្រែគោលជំហររបស់ខ្លួន ដោយលើកឡើងថា ស្ថាប័នតុលាការរបស់ អ.វ.ត.ក មានអំណាចក្នុងការចាត់វិធានការតាមឆន្ទានុសិទ្ធិ អនុលោមតាមវិធាន ៣៥ *ផ្អែកតាមការអនុវត្តដោយភាគីនៃកិច្ចដំណើរការនីតិវិធី*[98]។ ពុំមានចំណុចណាមួយនៅក្នុងវិធាន ៣៥ លើកឡើងផ្សេងពីនេះទេ និងតាមរយៈលក្ខណៈ និងគោលបំណងនៃបទប្បញ្ញត្តិ នេះពិតជាវិធីសាស្ត្រត្រឹមត្រូវ។ គោលជំហរផ្សេងទៀតណាមួយក៏ដោយនឹងចាត់ទុកជាជោគជ័យមិនយុត្តិធម៌នៃទម្រង់លើអង្គសេចក្តី។ មេធាវីក៏ដូចជាចៅក្រមដែរ មានកាតព្វកិច្ចធានាអំពីសុចរិតភាពនៃកិច្ចដំណើរការនីតិវិធី (អនុលោមតាមក្រមសីលធម៌រៀងៗខ្លួន)។ វានឹងក្លាយជាមូលហេតុមិនសមហេតុផលក្នុងការលើកឡើង ថា មេធាវីសម្រាប់ភាគីមួយមិនអាចស្នើសុំឱ្យអង្គជំនុំជម្រះធ្វើការបកស្រាយ ស្របតាមវិធាន ៣៥ នោះ។ នៅពេលត្រូវបានលើកឡើងដោយតុលាការធម្មនុញ្ញអ៊ូហ្គង់ដាថ្មីៗនេះ (ទោះបីនៅក្នុងបរិបទ ខុសគ្នាក៏ដោយ): តុលាការមិនត្រូវ "ធ្វើមិនដឹងមិនឮចំពោះអនីត្យានុកូលភាពដែលត្រូវបានចោទប្រកាន់នោះទេ និងមានកាតព្វកិច្ចធ្វើការស៊ើបអង្កេតលើការចោទប្រកាន់នោះ"[99]។ ហេតុនេះ គោលជំហររបស់អង្គជំនុំជម្រះសាលាដំបូងគឺមានន័យស្មើនឹង "កំហុសលើអង្គច្បាប់"[100]។

---

[97] សេចក្តីសម្រេចដែលរងការជំទាស់ ជើងទំព័រលេខ ៤៥។

[98] *សូមមើល* កថាខណ្ឌ ១៨ *ខាងលើ*។

[99] រឿងក្តី *Kwoyelo* តទល់នឹង *Uganada* តុលាការធម្មនុញ្ញរបស់ប្រទេសអ៊ូហ្គង់ដា ញត្តិលេខ ០៣៦/១១ "សេចក្តីសម្រេចរបស់តុលាការ" ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ ២០១១ ទំព័រ ៦:៣១-១៣៣។ កំណត់សម្គាល់ វិធាន ៣៥ ជាការចងក្រងជាផ្នែកមួយដ៏សំខាន់នៃអំណាចដែលមានរបស់ អ.វ.ត.ក។ សូមមើល ឧទាហរណ៍ ឯកសារ "បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ១១" ចុះថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០០៩ ERN 00323238–00323255 កថាខណ្ឌ ១០ ដល់ ១២ (អំណាចដែលមានគឺជាអំណាចទាំងឡាយដែលមិនមែនបានមកពីលក្ខន្តិកៈ ឬការបញ្ជាក់ពីការផ្តល់អំណាចផ្សេងទៀតនោះទេ តែគឺបានមកពីលក្ខណៈផ្ទាល់របស់តុលាការ)។

[100] សេចក្តីសម្រេចលើសំណើសុំដោះលែង កថាខណ្ឌ ២៧។ *កំណត់សម្គាល់* អង្គជំនុំជម្រះសាលាដំបូងមិនបានបដិសេធសំណើសុំតាមវិធាន ៣៥ ដោយផ្អែកលើមូលដ្ឋាននេះទេ។ ទោះបីជាយ៉ាងណាក៏ដោយ ជាប្រយោជន៍ដល់ការបង្កើន "ការអនុវត្តរបស់តុលាការ" នូវវិធាន ៣៥ នៅ អ.វ.ត.ក គោលជំហរភ័ន្តច្រឡំដែលត្រូវបានបញ្ជាក់នៅក្នុងសេចក្តីសម្រេចដែលរងការជំទាស់ ទោះបីជាយ៉ាងណាគួរតែត្រូវបានលើកឡើងដោយអង្គជំនុំជម្រះតុលាការកំពូល។

## គ. អង្គជំនុំជម្រះតុលាការកំពូលអាច និងគួរតែបំពេញតួនាទី លើបញ្ហាដែលមិនទាន់ដោះស្រាយនានា

៣៦. ចំពោះភាពធ្ងន់ធ្ងរនៃការចោទប្រកាន់នានាដែលត្រូវបានគូសបញ្ជាក់នៅក្នុងសំណើសុំ តាមវិធាន ៣៥ និងការគូសបញ្ជាក់ខាងលើ ពុំមានបញ្ហាចោទទេថា អង្គជំនុំជម្រះសាលាដំបូងត្រូវបំពេញតួនាទី "ដោយគ្មានភាពរួញរា"។ ជាមួយនឹងភាពស្មុគស្មាញក្នុងការធ្វើដូច្នេះ ក៏ដូចជាគោលជំហរសម្រុះសម្រួលរបស់ ក.ស.ច.ស ទៅនឹងការចោទប្រកាន់នានា កាតព្វកិច្ចក្នុងការធានាអំពីសុចរិតភាពនៃកិច្ចដំណើរការនីតិវិធី និងសុចរិតភាពរបស់តុលាការ ពេលនេះគឺធ្លាក់លើអង្គជំនុំជម្រះតុលាការកំពូល។ វិធាន ៣៥(២) ផ្តល់ឱ្យ "អង្គជំនុំជម្រះណាមួយ" នូវអំណាចនេះ ហើយ - ដូចដែលបានលើកឡើងខាងលើ - ពុំមានលក្ខខណ្ឌកំណត់ផ្លូវច្បាប់ថា សេចក្តីអះអាងនានាអំពីការជ្រៀតជ្រែក ត្រូវតែមានការពាក់ព័ន្ធផ្ទាល់ទៅនឹងបញ្ហានានាដែលអង្គជំនុំជម្រះនេះបានទទួលឡើយ។

៣៧. និយាយបែបសាមញ្ញ ចៅក្រមទាំងឡាយនៃអង្គជំនុំជម្រះនេះអាច និងគួរតែធ្វើការស៊ើបអង្កេតលើការចោទប្រកាន់ដែលមិនទាន់ដោះស្រាយនានា អំពីការជ្រៀតជ្រែករបស់រាជរដ្ឋាភិបាលកម្ពុជា (ហើយប្រសិនបើចាំបាច់ ត្រូវផ្តន្ទាទោសចំពោះអ្នកទាំងឡាយដែលជាអ្នកទទួលខុសត្រូវ)[101]។ អង្គហេតុសត្យានុម័តនានា - ដូចជាលោក ហ៊ុន សែន, ខៀវ កាញារីទ្ធ និងពេលថ្មីៗនេះចៅក្រម Siegfried Blunk[102] - បានបង្ហាញជាភ័ស្តុតាងស្រាប់ (ដោយសន្មតថា ពាក្យសម្តីនានារក្សានូវអត្ថន័យសាមញ្ញនៅក្នុងបរិយាកាសវិសាមញ្ញ)។ ការជ្រៀតជ្រែករបស់រាជរដ្ឋាភិបាលកម្ពុជានោះដែលបានកើតឡើងយ៉ាងច្បាស់លាស់ បង្ហាញនូវភាពនីយភាពសំខាន់នៃការជ្រៀតជ្រែកផ្ទៃក្នុងដែលកាន់តែវែងឆ្ងាយនៅពីក្រោយរឿងរ៉ាវទាំងនេះ។ ហើយចំណុចមួយដែលប្រហែលជាបាត់ នៅក្នុងការរំជើបរំជួលថ្មីៗពាក់ព័ន្ធនឹងសំណុំរឿង ០០៣ និង ០០៤ គឺការជ្រៀតជ្រែកយ៉ាងសំខាន់: ដូចជារដ្ឋាភិបាលកំពុង*បដិសេធ*មិនឱ្យមានការចោទប្រកាន់បន្ថែមទៀត រដ្ឋាភិបាលកំពុងគាំទ្រការចោទ

---

[101] វិធាន ១០៤(១) ("សម្រាប់គោលបំណងទាំងនេះ អង្គជំនុំជម្រះតុលាការកំពូលអាចពិនិត្យមើលលើភស្តុតាង និងអំពាវនាវរកភស្តុតាងថ្មីដើម្បីសម្រេចលើបញ្ហានេះ")។

[102] ជាដំបូង ភាពស្មុគស្មាញក្នុងការលើកឡើងអំពីការងាររបស់ខ្លួននៅតុលាការ ចៅក្រម Blunk បានបញ្ចេញយោបល់គតសំថៃនៅក្នុងការវាយប្រហារយ៉ាងខ្លាំងក្លាប្រឆាំងនឹងអ្នកទាំងឡាយណាដែលបានធ្វើការរិះគន់អំពីវិធីសាស្ត្ររបស់ខ្លួនចំពោះសំណុំរឿង ០០៣ និង ០០៤។ *សូមមើល ឧទាហរណ៍* សេចក្តីប្រកាសព័ត៌មាន HRW ។

ប្រកាន់នាពេលបច្ចុប្បន្ន[103]។ នៅក្នុងបរិបទនៃគោលនយោបាយនានារបស់កម្ពុជា ការគាំទ្របែបនេះប្រាកដជាមានបង្កប់អត្ថន័យអ្វីផ្សេងទៀតមិនខាន។ ដើម្បីឱ្យច្បាស់ រាជរដ្ឋាភិបាលកម្ពុជាមានបានពិចារណា និងយល់ឃើញស៊ីសង្វាក់គ្នា ពាក់ព័ន្ធទៅនឹងបញ្ហាថា ទីបំផុត សំណុំរឿង ០០២ គួរត្រូវដោះស្រាយតាមវិធីណា[104]។ បញ្ហាចោទដែលនៅតែមានគឺ: ថាតើចៅក្រមកម្ពុជានៃតុលាការនេះគាំទ្រនាដកថារបស់រដ្ឋាភិបាល ដោយមិនត្រឹមត្រូវ ដល់កម្រិតណា។

៣៨. ជាមួយនឹងការដាក់ពាក្យលាឈប់ពីមុខងាររបស់ចៅក្រម Blunk អង្គជំនុំជម្រះនេះមិនអាចបដិសេធដោយជឿទុកចិត្តនូវការចោទប្រកាន់នានាដែលបានលើកឡើងនៅក្នុងសំណើសុំតាមវិធាន ៣៥ ឡើយ។ គេត្រូវតែមើលឃើញថា ការចាកចេញរបស់គាត់ មួយផ្នែក ជាការទទួលស្គាល់ជាផ្លូវការ នៃភាពធ្ងន់ធ្ងរ និងសច្ចៈសីលភាពនៃការជ្រៀតជ្រែករបស់រាជរដ្ឋាភិបាលនៅតុលាការនេះ។ ទោះបីជាមេធាវីការពារក្តីចង់ដឹងចង់ឮថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ "បានផ្តើមនីតិវិធីស្តីពីការប្រមាថតុលាការប្រឆាំងនឹង [រដ្ឋមន្ត្រីក្រសួងព័ត៌មានរបស់រាជរដ្ឋាភិបាល]" ចំពោះការជ្រៀតជ្រែកយ៉ាងច្បាស់លាស់ បើកចំហ និងដែលឥតសំចៃមាត់របស់គាត់យ៉ាងណាក៏ដោយ ក៏ការបញ្ចេញឱ្យដឹងជាសាធារណៈរបស់ចៅក្រមអំពីសកម្មភាពសម្ងាត់ តាមការសន្មតនេះ - ដែលមានរយៈពេលប្រាំខែមកទល់នឹងពេលនេះក្រោយពេលដែលលោក ខៀវ កាញារីទ្ធ ផ្សព្វផ្សាយការកត់សម្គាល់របស់ខ្លួន - បានកន្លងហួសយូរហើយ។ ប្រសិនបើចៅក្រម Blunk ពិតជាបានសង្ឃឹមថា សកម្មភាពរបស់ខ្លួន អាចយកធ្វើជា "ការព្រមានដល់មន្ត្រីរដ្ឋាភិបាលផ្សេងៗទៀត" មេធាវី ការពារក្តីត្រូវបានបង្ខំឱ្យយល់ថា តើគោលបំណងនេះអាចត្រូវបានសម្រេចជោគជ័យជាសម្ងាត់ តាមវិធីណា។ ការព្រមានដែលបិទជិតគឺមិនមានការព្រមានទាល់តែសោះ។ ដោយផ្តល់នូវ ការកត់សម្គាល់ថ្មីៗរបស់រដ្ឋមន្ត្រីក្រសួងការបរទេសរបស់រាជរដ្ឋាភិបាលកម្ពុជា ការប៉ុនប៉ងប្រកបដោយអត្ថន័យល្អរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំមានអានុភាពទប់ស្កាត់នោះទេ។ ដើម្បីទទួលបានជោគជ័យទៅលើអ្វីដែលចៅក្រម Blunk បានបរាជ័យ អង្គជំនុំជម្រះនេះត្រូវតែបំពេញតួនាទីដោយការបើកចំហ យ៉ាងរឹងមាំ និងដោយគ្មានការពន្យារពេល។

---

[103] *កំណត់សម្គាល់* នៅពេលដែល ក.ស.ច.ស ស្ថិតក្រោមការដឹកនាំរបស់ចៅក្រម Marcel Lemonde និងចៅក្រម យូ ប៊ុនឡេង ហាក់ដូចជាផ្តោតតែលើភស្តុតាងដាក់បន្ទុកតែមួយប៉ុណ្ណោះ នៅក្នុងសំណុំរឿង ០០២ ការិយាល័យដែលស្ថិតនៅក្នុង ការកំណើតជាថ្មីនាបច្ចុប្បន្ននេះ បានវិវត្តន៍ (ស្ទើរតែគ្រប់ដំណើររឿងទាំងអស់) នូវសម្ព័ន្ធភាពដ៏រឹងមាំសម្រាប់ភស្តុតាងដោះ បន្ទុក។

[104] *សូមមើល ឧទាហរណ៍* Hall Op-Ed ("ដោយបានរាំងស្ទះតុលាការ លោក ហ៊ុន សែន នៅតែអាចត្រួតត្រាគោលនយោបាយនៃនីតិវិធី នៅពេលរៀបចំគម្រោងនៃសម័យខ្មែរក្រហមផងដែរ ដូច្នេះមានតែបុគ្គលបីបួននាក់ប៉ុណ្ណោះដែលទំនងជាមានពិរុទ្ធ")។

៣៩. ដូចដែល Mark Ellis បានធ្វើការព្រមានយ៉ាងសក្តិសមថា អន្តរាយរបស់ចេតនាសុចរិតនៃភាពសុទិដ្ឋិនិយមផ្នែកតុលាការអាចជាបញ្ហាតិចតួច តែនៅពេលដំណាលគ្នានោះវាក៏អាចបង្កបញ្ហាធំដំដែរ។ កម្លាំងចលករនៃស្ថាប័ន - ដូចជា ការជ្រៀតជ្រែករបស់អង្គនីតិប្រតិបត្តិចូលក្នុងរដ្ឋដែលប្រើអំណាចផ្តាច់ការ - មិនជម្នះបានដោយងាយស្រួលឡើយ។ រឿងជាច្រើនអាចនឹង មានផលអាក្រក់ខ្លាំង: ដូចជា ការជំនុំជម្រះទោសប្រកបដោយភាពយុត្តិធម៌សម្រាប់ជនជាប់ចោទ ទាំងបួននាក់ សុចរិតភាពរបស់តុលាការ និងកេរ្តិ៍ឈ្មោះផ្ទាល់ខ្លួន និងវិជ្ជាជីវៈ (ដែលមិនមែន មិនសំខាន់ទេ) របស់អ្នកទាំងឡាយណា ដែលទទួលខុសត្រូវចំពោះមុខកិច្ចដំណើរការ នីតិវិធីទាំងអស់នេះ។ ជាការពិត មេធាវីការពារក្តីខ្លួនឯងអាចនឹងប្រឈមជាមួយនឹងកាតព្វកិច្ចពិបាកនាពេលឆាប់ៗនេះក្នុងការផ្តល់ប្រឹក្សាដល់លោក នួន ជា ពាក់ព័ន្ធនឹងបញ្ហាថាតើ ការចូលរួម តទៅទៀតនៅក្នុងការជំនុំជម្រះនេះត្រូវបានធានាដែរឬទេ។ ដូចនៅក្នុងកិច្ចប្រឹងប្រែងនានា ដែលចំណុចខ្សោយរបស់ខ្លួនត្រូវបានលាតត្រដាង និងអាចយល់បានបន្តិចម្តងៗ វាឈានដល់ចំណុចមួយ នៅពេលដែលភាពស្ងៀមស្ងាត់ ភាពអសកម្ម និងការគេចចេញដោយចេតនាពីការសម្រេចដែលពិបាក វិវត្តន៍ក្លាយទៅជាភាពស្មុគស្មាញ[105]។ ជាអកុសល អ.វ.ត.ក កំពុងតែឈានដល់ដំណាក់កាលនេះយ៉ាងឆាប់រហ័ស[106]។

## ឃ. សវនាការផ្ទាល់មាត់នឹងបម្រើផលប្រយោជន៍នៃយុត្តិធម៌

៤០. មានការសន្មតទុកជាមុនថា សវនាការលើបណ្តឹងសាទុក្ខ "ត្រូវធ្វើឡើងជាសាធារណៈ"[107]។ ទោះបីជាវិធានផ្ទៃក្នុងចែងអំពីការសម្រេចលើ "បណ្តឹងសាទុក្ខភ្លាមៗដោយផ្អែកតែលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរប៉ុណ្ណោះ"[108] ក៏ដោយ ក៏សារៈសំខាន់នៃបញ្ហាផ្សេងៗដែលបានលើកឡើងក្នុងបណ្តឹងសាទុក្ខនេះ ស្នើសុំឱ្យមានកិច្ចពិភាក្សាគ្នាជាសាធារណៈដ៏ពេញលេញ និងស្មោះត្រង់មួយ។ អង្គការសហប្រជាជាតិត្រូវបានចោទប្រកាន់ថា "បានធ្វើមិនដឹងមិនឮចំពោះបញ្ហាដោយខកខានមិនបានឆ្លើយតបទៅនឹងការចោទប្រកាន់ដែលអាចជឿទុកចិត្តបានជាច្រើន អំពីការ

---

[105] *កំណត់សម្គាល់* លើកលែងតែ និងលុះត្រាតែ នួន ជា ផ្តល់ការណែនាំផ្ទុយពីនេះ មេធាវីការពារក្តីនឹងនៅតែនិយាយ បំពេញការងារ និងសួរសំណួរទាំងនេះដោយឥតសំចៃ។

[106] *សូមមើល ឧទាហរណ៍* Hall Op-Ed ("ពេលនេះ ការជ្រៀតជ្រែកផ្នែកនយោបាយបានលុបចោលយ៉ាងច្បាស់លាស់នូវឯករាជ្យភាព និងភាពអនាគតិរបស់អង្គតុលាការ") (សេចក្តីបញ្ជាក់បន្ថែម)។

[107] វិធាន ១០៩(១)។

[108] *ដូចខាងលើ* ("អង្គជំនុំជម្រះអាចសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗដោយផ្អែកតែលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយ-លក្ខណ៍អក្សរប៉ុណ្ណោះ")។

ប្រព្រឹត្តខុសរបស់តុលាការ"[109]។ ជាជាងធ្វើតាមទង្វើពីមុនដ៏គួរឱ្យអាម៉ាស់នេះ អង្គជំនុំជម្រះតុលាការកំពូលគួរតែរក្សាកេរ្តិ៍ឈ្មោះរបស់ខ្លួន និងដាក់ អ.វ.ត.ក និងរាជរដ្ឋាភិបាលកម្ពុជាឱ្យនៅក្រោមការពិនិត្យពិច័យជាសាធារណៈ ដែលស្ថាប័នវិសាមញ្ញទាំងពីរនេះសមនឹងទទួល។

## V. សេចក្តីសន្និដ្ឋាន

៤១. ហេតុនេះ សម្រាប់សំអាងហេតុនានាដែលបានលើកឡើងនៅពេលនេះ អង្គជំនុំជម្រះនេះគួរតែ:

ក. ទទួលយកបណ្តឹងសាទុក្ខភ្លាមៗនេះ។

ខ. ប្រកាសថា សេចក្តីសម្រេចដែលរងការជំទាស់គ្មានសុពលភាពទេ ដោយមូលហេតុនានាដែលបានលើកឡើងខាងលើ។

គ. បង្គាប់ឱ្យមានការស៊ើបអង្កេតជាសាធារណៈ អនុលោមតាមវិធាន ៣៥ ស្របតាមបែបបទពិសេសដែលបានកំណត់នៅកថាខណ្ឌ ៣២ នៃសំណើសុំតាមវិធាន ៣៥ ដែលត្រូវធ្វើឡើងដោយផ្នែកមួយរបស់តុលាការ (ដែលត្រូវបានបង្ហាញឱ្យឃើញថាមានឯករាជ្យភាព) ដោយមិនបញ្ចូលនូវបុគ្គលជាក់លាក់ណាមួយ ដែលការប្រព្រឹត្តដែលត្រូវបានចោទប្រកាន់របស់បុគ្គលនោះបង្កើតបានជាមូលដ្ឋានអង្គហេតុ ដែលមាននៅក្នុងសំណើសុំតាមវិធាន ៣៥ និងបណ្តឹងសាទុក្ខភ្លាមៗនេះ។ និង

ឃ. បំពេញកិច្ចស៊ើបសួរដំបូង និងអនុវត្តការស៊ើបអង្កេតនៅពេលបន្ទាប់ និង/ឬ វិធានការដាក់វិន័យ មុនពេលសវនាការលើអង្គសេចក្តីនៅក្នុងសំណុំរឿង ០០២។

ដូចដែលបានកត់សម្គាល់ខាងលើ ការផ្តល់ទឡ្ហីករណ៍ផ្ទាល់មាត់នៅពេលសវនាការសាធារណៈនៅមុនពេលសម្រេចសេចក្តីណាមួយគឺជាការត្រឹមត្រូវ អាស្រ័យហេតុនេះបណ្តឹងសាទុក្ខនេះស្នើសុំឱ្យមានការរៀបចំសវនាការ ដើម្បីស្តាប់ទឡ្ហីករណ៍ផ្ទាល់មាត់។

សហមេធាវីការពារក្តីលោក នួន ជា

សុន អរុណ Michiel PESTMAN & Victor KOPPE

[109] សេចក្តីប្រកាសព័ត៌មាន HRW ។